ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា
CAMBODIAN DEFENDERS PROJECT
Promoting Human Rights by Strengthening Rule of Law, Legal System and Liberal Democracy

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

កម្មវិធីសុខភាពផ្លូវចិត្ត
TPO
អង្គការចិត្តសង្គម វប្បធម៌
Transcultural Psychosocial Organization
Community Mental Health Programme

គម្រោងស្តីពី "ការលើកកម្ពស់សមភាពយេនឌ័រ និងការធ្វើឲ្យប្រសើរឡើងនូវលទ្ធភាពទទួលបានយុត្តិធម៌របស់អ្នករស់រានមានជីវិតជាស្ត្រី និងជនរងគ្រោះដោយសារអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រក្នុងរបបខ្មែរក្រហម"

របាយការណ៍ស្តីពីការសិក្សាដើម្បីចងក្រងទិន្នន័យមូលដ្ឋានរបស់អង្គការមិនមែនរដ្ឋាភិបាល

របាយការណ៍ស្តីពីលទ្ធផលនៃការសិក្សាដើម្បីចងក្រងទិន្នន័យមូលដ្ឋាន ការយល់ដឹងយេនឌ័រក្នុងដំណើរការយុត្តិធម៌អន្តរកាលនៅក្នុងប្រទេសកម្ពុជា

ខែ ឧសភា ឆ្នាំ ២០១២

ភ្នំពេញ ប្រទេសកម្ពុជា

ដោយកញ្ញា ណយ សុផារី អ្នកជំនាញកម្ពុជា

ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា
CAMBODIAN DEFENDERS PROJECT
Promoting Human Rights by Strengthening Rule of Law, Legal System and Liberal Democracy

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គការចិត្តសង្គម វប្បធម៌
Transcultural Psychosocial Organization
Community Mental Health Programme

របាយការណ៍ស្តីពីការសិក្សាដើម្បីចងក្រងទិន្នន័យមូលដ្ឋានរបស់អង្គការមិនមែនរដ្ឋាភិបាល

របាយការណ៍ស្តីពីលទ្ធផលនៃការសិក្សាដើម្បីចងក្រងទិន្នន័យមូលដ្ឋាន ការយល់ដឹងយេនឌ័រក្នុងដំណើរការយុត្តិធម៌អន្តរកាលនៅក្នុងប្រទេសកម្ពុជា

គម្រោងស្តីពី "ការលើកកម្ពស់សមភាពយេនឌ័រ និងការធ្វើឲ្យប្រសើរឡើងនូវលទ្ធភាពទទួលបានយុត្តិធម៌របស់អ្នករស់រានមានជីវិតជាស្ត្រី និងជនរងគ្រោះដោយសារអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រក្នុងរបបខ្មែរក្រហម"

ដោយកញ្ញា ណាយ សុផារី អ្នកជំនាញកម្ពុជា

ខែ ឧសភា ឆ្នាំ ២០១២

ភ្នំពេញ ប្រទេសកម្ពុជា

សេចក្តីថ្លែងអំណរគុណ

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងស្មោះចំពោះអ្នកចូលរួមក្នុងការស្រាវជ្រាវនេះដែលបានចំណាយពេលវេលា និងការចូលរួមជាវិភាគទាន ទាំងការផ្តល់បទសម្ភាស និងផ្តល់ជាមតិកែលម្អក្នុងអំឡុងពេលសិក្ខាសាលានៃការធ្វើបទបង្ហាញលទ្ធផលបឋម។ អ្នកចូលរួមបានចែករំលែកបញ្ហាប្រឈម និងបទពិសោធន៍ល្អៗដែលអាចនាំដល់លទ្ធផលឆ្លើយតបយេនឌ័រ។ ទាំងនេះអាចឲ្យខ្ញុំកំណត់បានទ្បូវឧបសគ្គទាក់ទងនឹងការយល់ដឹងពីយេនឌ័រ ក្នុងការអនុវត្តជាក់ស្តែង និងសកម្មភាពរបស់អង្គការសង្គមស៊ីវិល (CSOs)។

សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅដល់បុគ្គលិកទាំងអស់នៃអង្គភាពគាំពារជនរងគ្រោះ (VSS) នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) និងសូមថ្លែងអំណរគុណជាពិសេសដល់អ្នកស្រី ហេង គីមហ៊ុច ដែលបានផ្តល់ការសម្របសម្រួលបានយ៉ាងល្អ និងផ្តល់ជាជំនួយផ្នែករដ្ឋបាលក្នុងអំឡុងពេលស្រាវជ្រាវនេះ។ ខ្ញុំក៏សូមថ្លែងអំណរគុណជាពិសេសដល់ លោក អ៊ឹម សុភា ប្រធានកម្មវិធីផ្សព្វផ្សាយនៃអង្គភាពគាំពារជនរងគ្រោះ នៃអ.វ.ត.ក ដែលបានផ្តល់គោលការណ៍ណែនាំក្នុងការរៀបចំគម្រោងគំនិតសម្រាប់ការស្រាវជ្រាវ ដោយ កំណត់ពីអ្នកចូលរួមនៅក្នុងការស្រាវជ្រាវនេះ និងសម្របសម្រួលសិក្ខាសាលា ស្តីពីការស្រាវជ្រាវចងក្រងទិន្នន័យមូលដ្ឋានជាមួយអង្គការមិនមែនរដ្ឋាភិបាល។

ដូចគ្នានេះដែរ ខ្ញុំក៏សូមថ្លែងអំណរគុណដល់ លោក ដួង សាវន មន្ត្រីសម្របសម្រួលគម្រោងអំពើហិង្សាលើយេនឌ័ររបស់ក្រុមអ្នកការពារសិទ្ធិកម្ពុជា (CDP) និងអ្នកស្រី Judith Strasser ទីប្រឹក្សាជាន់ខ្ពស់របស់អង្គការGIZ ប្រចាំអង្គការចិត្តសង្គមអន្តរវប្បធម៌ (TPO) ដែលបានផ្តល់គំនិតសម្រាប់រៀបចំការស្រាវជ្រាវនេះ។

ខ្ញុំសូមសំដែងការដឹងគុណដ៏ជ្រាលជ្រៅចំពោះ អ្នកស្រី Alison Barclay ទីប្រឹក្សាផ្នែកយេនឌ័ររបស់ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា (CDP) អ្នកស្រី Beini Ye ទីប្រឹក្សាជាន់ខ្ពស់របស់អង្គការ GIZ ប្រចាំក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជាដែលបានផ្តល់ជាអនុសាសន៍ការគាំទ្រ និងការណែនាំដ៏មានតម្លៃក្នុងដំណាក់កាលសរសេររបាយការណ៍ស្តីពីការស្រាវជ្រាវចងក្រងទិន្នន័យមូលដ្ឋានជាមួយនឹងអង្គការមិនមែនរដ្ឋាភិបាល។ប្រសិនបើគ្មាន អ្នកទាំងនោះទេ របាយការណ៍នេះអាចពុំមានខ្លឹមសារច្បាស់លាស់ដូចនេះឡើយ។ អ្នកទាំងពីរក៏បានជួយកែសម្រួលខ្លឹមសាររបាយការណ៍នេះផងដែរ។

ជាចុងបញ្ចប់នេះ ខ្ញុំសូមផ្តែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ លោកស្រីបណ្ឌិត Theresa de Langis អ្នកជំនាញជាន់ខ្ពស់ និងជាសមភាគីអន្តរជាតិនៃគម្រោងស្រាវជ្រាវនេះ ដែលបានដឹកនាំក្នុងរៀបចំគម្រោងគំនិតសម្រាប់ការស្រាវជ្រាវ និងសូចនាករសំខាន់ៗ។ បទពិសោធ របស់លោកស្រីលើផ្នែកសិទ្ធិស្ត្រីក្នុងស្ថានភាពក្រោយជម្លោះបានជួយខ្ញុំឲ្យធានាដល់សុក្រឹតភាពក្នុងការវិភាគទិន្នន័យ។

ខ្ញុំសូមឧទ្ទិសរបាយការណ៍នេះជូនទៅជនរងគ្រោះ និងអ្នករស់រានមានជីវិតពីរបបប៉ុលពតដែលព្យាយាមតស៊ូដើម្បីរស់ និងបានចែករំលែកចំណេះដឹងពីតួនាទីរបស់ស្ត្រីក្នុងការស្តារសង្គមឡើងវិញពីអំពើឃោរឃៅ យ៉ាងរង្គាល។ ការខិតខំប្រឹងប្រែងរបស់គេបានជំរុញឲ្យមានកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀតក្នុងការស្វែងរកយុត្តិធម៌ និងជំរុញឲ្យមានការផ្សះផ្សាជាតិ ។

របាយការណ៍ស្តីពីលទ្ធផលស្រាវជ្រាវដើម្បីចងក្រងទិន្នន័យមូលដ្ឋានជាមួយអង្គការមិនមែនរដ្ឋាភិបាលការស្រាវជ្រាវដើម្បីចងក្រងទិន្នន័យជាមូលដ្ឋានស្តីពីការយល់ដឹងយេនឌ័រក្នុងដំណើរការនីតិវិធីយុត្តិធម៌អន្តរកាលក្នុងប្រទេសកម្ពុជា

អង្គភាពគាំពារជនរងគ្រោះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ដោយកញ្ញា ណយ សុផារី អ្នកជំនាញកម្ពុជា

១. សេចក្តីផ្តើម

យុត្តិធម៌អន្តរកាលគឺជាកម្រងយន្តការដែលត្រូវបានយកមកប្រើប្រាស់ដើម្បីឈានទៅដោះស្រាយការរំលោភសិទ្ធិមនុស្សដែលបានប្រព្រឹត្តកាលពីអតីតកាល។ បន្ទាប់ពីបានអនុវត្តមួយរយៈមក យុត្តិធម៌អន្តរកាលបានក្លាយជាផ្នែកមួយយ៉ាងចាំបាច់នៃកិច្ចខិតខំប្រឹងប្រែងនៅថ្នាក់ជាតិ និងអន្តរជាតិ ដើម្បីពង្រឹងវិធានច្បាប់ និងលើកកម្ពស់ការគោរពសិទ្ធិមនុស្សបន្ទាប់ពីមានជម្លោះ និងជាកត្តាយ៉ាងសំខាន់នៃរបៀបវារៈកសាងសន្តិភាពក្នុងប្រទេស ដែលទើបងើបចេញពីសង្គ្រាមស៊ីវិលរ៉ាំរ៉ៃ។

ដោយសារតែមានកំណើនតួនាទីរបស់អង្គការសហប្រជាជាតិក្នុងការផ្តល់ជាជំនួយបច្ចេកទេស និងថវិកាក្នុងដំណើរការយុត្តិធម៌អន្តរកាលនោះ ទើបអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ទទួលបានគម្រោងមួយពីមូលនិធិបម្រុងពិសេសរបស់អង្គការសហប្រជាជាតិដើម្បីបញ្ឈប់អំពើហិង្សាលើស្ត្រីដែលមានឈ្មោះថា *"ការលើកកម្ពស់សមភាពយេនឌ័រ និងការធ្វើឲ្យប្រសើរឡើងនូវលទ្ធភាពទទួលបានយុត្តិធម៌របស់អ្នករស់រានមានជីវិតជាស្ត្រី និងជនរងគ្រោះដោយសារអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រក្នុងរបបខ្មែរក្រហម"* ចាប់ពីឆ្នាំ ២០១១ ដល់ឆ្នាំ ២០១៤។ អ.វ.ត.ក នឹងអនុវត្តគម្រោងនេះដោយសហការជាមួយអង្គការមិនមែនរដ្ឋាភិបាលកម្ពុជាចំនួន២ (NGOs) ដូចជា ក្រុមអ្នកច្បាប់ការពារសិទ្ធិមនុស្សនៅកម្ពុជា (CDP) និងអង្គការចិត្តសង្គមអន្តរវប្បធម៌ (TPO)។

គោលដៅរបស់កម្មវិធី គឺដើម្បីលើកកម្ពស់សមភាពយេនឌ័រ និងធ្វើឲ្យប្រសើរឡើងនូវលទ្ធភាពទទួលបានយុត្តិធម៌របស់អ្នករស់រានមានជីវិតជាស្ត្រី និងជនរងគ្រោះដោយសារអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ (GBV) ក្នុងរបបខ្មែរក្រហមតាមរយៈការលើកកម្ពស់ការយល់ដឹងយេនឌ័រក្នុងដំណើរការ និងសកម្មភាពរបស់ អ.វ.ត.ក អង្គការសង្គមស៊ីវិល និងស្ថាប័នអប់រំវិជ្ជាជីវៈចៅក្រម ដែលការធ្វើដូចនេះអាចជួយដល់ការទប់ស្កាត់អំពើហិង្សាយេនឌ័រ និងបង្កើនលទ្ធភាពទទួលបានយុត្តិធម៌របស់អ្នករស់រានមានជីវិតពីអំពើហិង្សាយេនឌ័រទាំងអស់។

តាមការរំពឹងទុកថា ការសិក្សាជាមូលដ្ឋាននេះនឹងចូលរួមចំណែកដល់ការបង្កើតគម្រោងផ្លូចផ្តើមយុត្តិធម៌អន្តរកាលទូលំទូលាយស្តីពីការយល់ដឹងយេនឌ័រជាមួយ អ.វ.ត.ក និងអង្គការសង្គមស៊ីវិល។ នៅពេលដែលការ ស្រាវជ្រាវចងក្រងទិន្នន័យមូលដ្ឋាន (ការស្រាវជ្រាវចងក្រងទិន្នន័យមូលដ្ឋានរបស់ អ.វ.ត.ក) ត្រូវបានធ្វើឡើងដើម្បីវាស់ស្ទង់ពីសកម្មភាពរបស់ អ.វ.ត.ក ទាក់ទងនឹងការឆ្លើយតបទៅនឹងយេនឌ័រក៏ដោយ ក៏ការស្រាវជ្រាវចងក្រងទិន្នន័យមូលដ្ឋាននេះ (ការស្រាវជ្រាវចងក្រងទិន្នន័យមូលដ្ឋានជាមួយអង្គការមិនមែនរដ្ឋាភិបាល) ក៏ត្រូវបានយកមកប្រើប្រាស់ដើម្បីវាស់វែងពីវិសាលភាពនៃការបញ្ជាបយេនឌ័រក្នុងអង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធនានា និងប្រើជាសូចនាករមួយនៃការយល់ដឹង យេនឌ័រពាក់ព័ន្ធនឹងបញ្ហាយុត្តិធម៌អន្តរកាល ជាពិសេសទាក់ទងនឹងការឆ្លើយតបនឹងអំពើហិង្សាយេនឌ័រ។ ដូចនេះ ជារួម វិសាលភាពនៃការបញ្ជាបយេនឌ័រអាចប្រើជាសូចនាករគ្រប់គ្រងសម្រាប់ជាមូលដ្ឋាននៃការសិក្សា ដោយកំណត់យុទ្ធសាស្ត្របញ្ជាបយេនឌ័រថាជា ៖ "ការបញ្ជាបយេនឌ័របង្ហាញថា កង្វល់ និងបទពិសោធរបស់បុរស និងស្ត្រី គឺជាកត្តាយ៉ាងសំខាន់ដើម្បីរៀបចំ អនុវត្ត ត្រួតពិនិត្យ និងវាយតម្លៃកម្មវិធី និងសេវាដើម្បីឲ្យស្ត្រី និងបុរសទទួលបានអត្ថប្រយោជន៍ស្មើៗគ្នា និងគ្មានវិសមភាពទៀតឡើយ[1]។

"យុត្តិធម៌បន្ទាប់ពីការកែប្រែរបបនយោបាយ មិនត្រឹមដោះស្រាយផលវិបាកនៃការរំលោភបំពានដែលបានប្រព្រឹត្តក្នុងអំឡុងពេលមានជម្លោះប៉ុណ្ណោះទេ ថែមទាំងបង្ហាញពីទំនាក់ទំនងសង្គមដែលអាចធ្វើឲ្យមានការរំលោភបំពានទាំងនេះកើតឡើង ជាដំបូង ហើយកត្តានេះរួមបញ្ចូលទាំងការកែតម្រូវទំនាក់ទំនងអំណាចដែលនាំឲ្យមានវិសមភាពយេនឌ័រក្នុងសង្គម។ Rashidamanjoo តំណាងពិសេសរបស់អង្គការសហប្រជាជាតិប្រឆាំងនឹងអំពើហិង្សាលើស្ត្រី មូលហេតុ និងផលវិបាកនៃអំពើហិង្សាទាំងនេះ"។

សមភាពយេនឌ័រអាចឆ្លុះបញ្ចាំងតាមរយៈគោលបំណងច្បាស់លាស់ក្នុងការបញ្ជាបយេនឌ័រ។ គេមានការយល់ដឹងកាន់តែច្រើនឡើងពីតួនាទីស្នូលក្នុងសកម្មភាពរបស់អង្គការក្នុងការរៀបចំ និងផ្សព្វផ្សាយពីកម្មវិធី និងគម្រោងយល់ដឹងយេនឌ័រ[2]។ ក្នុងបរិបទស្ថាប័ន យេនឌ័រគឺ "ផ្នែកមួយដ៏សំខាន់សម្រាប់ការសម្រេច និងបទ អន្តរាគមន៍ទាំងអស់ រួមមានការជ្រើសរើស និងដាក់បុគ្គលិក នីតិវិធី និងកម្មវិធី និងជាចំណុចសំខាន់នៃការទទួលខុសត្រូវរបស់បុគ្គលិកទាំងអស់"[3]។ ហេតុដូច្នេះ ការស្រាវជ្រាវចងក្រងទិន្នន័យមូលដ្ឋាននេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណង

[1] Caroline Moser "សេចក្តីផ្តើមអំពីវិធីសាស្ត្រសវនកម្មយេនឌ័រ ៖ ការរៀបចំ និងការអនុវត្តក្នុង DFID Malawi វិទ្យាស្ថានអភិវឌ្ឍន៍ក្រៅប្រទេស (ODI) ខែ ឧសភា ឆ្នាំ ២០០៥ ទំព័រទី១០។

[2] ដូចខាងលើ ទំព័រទី៤

[3] ដូចខាងលើ ទំព័រទី៩-១០

វាស់ស្ទង់ពីការបញ្ហាបយេនឌ័រ ទាំងនៅកម្រិតកម្មវិធី និងប្រតិបត្តិការរបស់អង្គ ការសង្គមស៊ីវិលក្នុងវិស័យយុត្តិធម៌អន្តរកាលក្នុងប្រទេសកម្ពុជា។

២. វិធីសាស្ត្រសិក្សា

ដើម្បីវាស់ស្ទង់ឲ្យបានជិតដល់នូវឥទ្ធិពលរបស់គម្រោង ទីប្រឹក្សាមកពីក្រៅចំនួនពីររូប[4]បានចុះកិច្ចសន្យាដើម្បីអនុវត្តការសិក្សាជាមូលដ្ឋានដែលត្រូវបានជួលដោយអង្គភាពគាំពារជនរងគ្រោះរបស់ អ.វ.ត.ក សហការជាមួយអង្គការដៃគូ CDP និង TPO។ យោងតាមលក្ខខណ្ឌបំពេញការងារ ការសិក្សាជាមូលដ្ឋាននេះមានគោលបំណងធ្វើឲ្យមានការយល់ដឹងកាន់តែច្បាស់អំពី “កិច្ចខិតខំប្រឹងប្រែងពីអតីតកាល និងបច្ចុប្បន្ន ក្នុងបញ្ហូលស្ត្រីទៅក្នុងដំណើរការយុត្តិធម៌អន្តរកាល និងវាយតម្លៃអំពីការយល់ដឹងពីបញ្ហាយេនឌ័រ និងតម្រូវការសម្រាប់ការកសាងសមត្ថភាពក្នុង អ.វ.ត.ក និងអង្គការសង្គមស៊ីវិល ដែលកំពុងធ្វើការក្នុងបរិបទតុលាការខ្មែរក្រហម”។ ការវាយតម្លៃនេះនឹងយកមកប្រើប្រាស់ដើម្បីឲ្យយល់ដឹងពីកម្មវិធីទាំងមូលស្តីពីអន្តរកាលស្វែងរកយុត្តិធម៌ពីការរងគ្រោះដោយសារយេនឌ័រ ដោយផ្តោតលើការកសាងសមត្ថភាព ជំនួយចិត្តសាស្ត្រ-សង្គម ការនិយាយពីការពិត ក្នុងសហគមន៍ និងការលើកកម្ពស់ការផ្សព្វផ្សាយសំណងជានិមិត្តរូបនិងការចងក្រងឯកសារជាប្រវត្តិសាស្ត្រដោយ រួមបញ្ចូលស្ត្រី។

ដើម្បីសម្រេចបានគោលបំណងនៃការស្រាវជ្រាវចងក្រងទិន្នន័យមូលដ្ឋាននេះ កម្រងសំណួរសម្រាប់សម្ភាស ក្នុងនោះមានសូចនាករសំខាន់ៗដើម្បីវាស់ស្ទង់ពីការឆ្លើយតបយេនឌ័រក្នុងដំណើរការយុត្តិធម៌អន្តរកាល ត្រូវបានរៀបចំឡើងដើម្បីវាយតម្លៃពីសមត្ថភាពយេនឌ័រក្នុងពេលបច្ចុប្បន្ន និងការយល់ដឹងយេនឌ័ររបស់អង្គការមិនមែនរដ្ឋាភិបាលដែលបំពេញការងារពាក់ព័ន្ធកិច្ចខិតខំប្រឹងប្រែងក្នុងដំណើរការយុត្តិធម៌អន្តរកាលក្នុងប្រទេសកម្ពុជា។

តាមរយៈមាត្រដ្ឋាន ០-៥ អ្នកផ្តល់សម្ភាសត្រូវបានស្នើឲ្យដាក់ចំណាត់ថ្នាក់លើអនុវត្តសូចនាករនីមួយៗ ដោយផ្អែកលើចំណេះបច្ចុប្បន្នរបស់អ្នកផ្តល់បទសម្ភាស និងមានទំនាក់ទំនងជាមួយនឹងអង្គការរបស់ពួកគេ។ រាល់ចម្លើយទាំងអស់ត្រូវទៅផ្ទៀងផ្ទាត់ជាមធ្យមជាមួយនឹងចំណាត់ថ្នាក់ដែលមានលេខ “៥” បង្ហាញពីការយល់ដឹងយ៉ាងខ្លាំង និងលេខ

[4] ទីប្រឹក្សាអន្តរជាតិ លោកស្រីបណ្ឌិត Theresa de langis អ្នកជំនាញជាន់ខ្ពស់ផ្នែកសិទ្ធិស្ត្រីក្នុងស្ថានភាពក្រោយជម្លោះ ទទួលខុសត្រូវលើការសិក្សាដើម្បីចងក្រងទិន្នន័យមូលដ្ឋានរបស់ អ.វ.ត.ក ចំណែកទីប្រឹក្សាជាតិ កញ្ញា ណយ សុផារី ទទួលខុសត្រូវការអនុវត្តការសិក្សាដើម្បីចងក្រងទិន្នន័យមូលដ្ឋានសម្រាប់អង្គការសង្គមស៊ីវិល។

“១” បង្ហាញថាមិនបានដឹង ឬពុំមានអត្ថិភាព។ ចំណាត់ថ្នាក់លេខ “0” បង្ហាញថា *“ខ្ញុំមិនដឹង”* ឬ “*មិនពាក់ព័ន្ធ*”។ មាត្រដ្ឋានវាយតម្លៃមានបង្ហាញនៅខាងក្រោម[5]។

បញ្ជីឈ្មោះអ្នកផ្តល់បទសម្ភាសសំខាន់ៗសម្រាប់ការសិក្សាជាមូលដ្ឋាននេះពីអង្គការមិនមែនរដ្ឋាភិបាលដែលមានការងារពាក់ព័ន្ធនឹងដំណើរការយុត្តិធម៌អន្តរកាលត្រូវបានជ្រើសរើសដោយធ្វើការពិគ្រោះយោបល់ប្រឹក្សាជាមួយអង្គភាពគាំពារជនរងគ្រោះ និងគម្រោងដៃគូ CDP និង TPO។ អង្គការមិនមែនរដ្ឋាភិបាលចំនួន ១៤ (ដប់បួន) និងសមាគមជនរងគ្រោះ ត្រូវបានជ្រើសរើសឱ្យចូលរួមក្នុងបទសម្ភាសដោយសារពួកគេមានកិច្ចការយ៉ាងសកម្ម ក្នុងការកិច្ចខិតខំប្រឹងប្រែងដើម្បីពង្រឹងដំណើរការយុត្តិធម៌អន្តរកាលតាមរយៈការអនុវត្តគម្រោងជាក់លាក់ទាក់ទងនឹងរបបខ្មែរក្រហម។ អង្គការមិនមែនរដ្ឋាភិបាលចំនួនពីរបានបដិសេធមិនផ្តល់សម្ភាសន៍។

លទ្ធផលចុងក្រោយពីបទសម្ភាសជាមួយអ្នកផ្តល់បទសម្ភាសសរុបចំនួន ១៥ រូប ក្នុងនោះ ១១ រូបមកពីអង្គការ មិនមែនរដ្ឋាភិបាលនិងមួយរូបមកពីសមាគមជនរងគ្រោះ។ អ្នកផ្តល់បទសម្ភាសម្នាក់ត្រូវបានផ្តល់អត្តសញ្ញាណ ផ្ទាល់ខ្លួនថាជាតំណាងក្នុងផ្នែកធ្វើសេចក្តីសម្រេច ឬប្រធានគ្រប់គ្រងកម្មវិធី ដែលទទួលខុសត្រូវលើការរៀបចំ និងអនុវត្តកម្មវិធីទាក់ទងនឹងខ្មែរក្រហម។ បទសម្ភាសទាំងនេះត្រូវបានធ្វើឡើងក្នុងការិយាល័យរបស់អ្នកផ្តល់បទសម្ភាសនីមួយៗ ចាប់ពីអាទិត្យនៃថ្ងៃទី ២០ ខែ កុម្ភៈ និងថ្ងៃទី ៥ ខែ មីនា ហើយបទសម្ភាសនីមួយៗអាចមានរយៈពេលជាមធ្យមពី ៤៥ នាទី ទៅ ៩០ នាទី។ ចម្លើយទាំងអស់ទទួលបានដោយមិនបង្ហាញឈ្មោះអ្នកផ្តល់បទសម្ភាសឡើយ ហើយចាត់ទុកជាព័ត៌មានសម្ងាត់។

អង្គការសង្គមស៊ីវិលដែលបានចូលរួមក្នុងការសិក្សាជាមូលដ្ឋានមានឈ្មោះតាមលំដាប់អក្ខរក្រមដូចខាងក្រោម[6] ៖

១. ADHOC ៖ សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (សមាគម អាដហុក)

២. ASF ៖ អង្គការមេធាវីគ្មានព្រំដែន បារាំង

៣. AIJI ៖ គម្រោងផ្តួចផ្តើមយុត្តិធម៌អន្តរកាលអាស៊ី

៤. CDP ៖ ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា

[5] សូមមើលគម្រោងទស្សនទានសម្រាប់ការពន្យល់ពេញលេញពីរបៀបបង្កើតសូចនាករទាក់ទងនឹងនិយមន័យនៃ “យុត្តិធម៌អន្តរកាល ពាក់ព័ន្ធនឹងការឆ្លើយតបយេនឌ័រ” និង “ការបញ្ជាបយេនឌ័រ” ដែលជាផ្នែកមួយយ៉ាងសំខាន់ដើម្បីវាស់ស្ទង់សម្រាប់ការសិក្សាដើម្បីចងក្រងទិន្នន័យមូលដ្ឋាន។

[6] លំដាប់លេខរៀងអង្គការមិនមែនរដ្ឋាភិបាល និងសមាគមជនរងគ្រោះ មិនស៊ីចង្វាក់គ្នានឹងលំដាប់ឈ្មោះអង្គការដែលមានក្នុងសូចនាករគោលឡើយ។

៥. CHRAC ៖ គណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការសមាគមការពារសិទ្ធិមនុស្សកម្ពុជា

៦. CD-Cam ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា

៧. ICfC ៖ មជ្ឈមណ្ឌលអន្តរជាតិសម្រាប់ការផ្សះផ្សា

៨. សមាគមជនរងគ្រោះក្បែមក្បាន្ត

៩. LAC ៖ អង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា

១០. TPO ៖ អង្គការចិត្តសង្គម-អន្តរវប្បធម៌

១១. YfP ៖ យុវសន្តិភាព

១២. YRDP ៖ កម្មវិធីអភិវឌ្ឍន៍ធនធានយុវជន

មាត្រដ្ឋានសម្រាប់កម្រងសំណួរ		
៥	លើសពីស្តង់ដារអប្បបរមា	សូចនាករលើសពី “ស្តង់ដារអប្បបរមា” សកម្មភាព យេនឌ័រល្អបំផុត
៤	មានស្តង់ដារអប្បបរមា	សូចនាករនេះកំពុងតែអនុវត្តយ៉ាងទូលំទូលាយ និងជាប្រចាំ ទាំងក្នុងគោលនយោបាយ និងការអនុវត្តជាក់ស្តែង។
៣	ត្រូវការការកែលម្អបន្ថែម	មានកិច្ចខិតខំប្រឹងប្រែងហើយ ប៉ុន្តែមានលក្ខណៈមិនអចិន្ត្រៃយ៍ មិនមានរៀបចំជាលក្ខណៈស្ថាប័ន ឬជាប្រព័ន្ធ ដែលមានឥទ្ធិពល ដល់លទ្ធផលចុងក្រោយ។
២	មានការខ្វះខាត	មានកិច្ចខិតខំប្រឹងតិចតួចដូចជាការយកតំណាងជាស្ត្រីក្នុងតួនាទីជាអ្នកដឹកនាំ និងធ្វើ សេចក្តីសម្រេចចិត្ត
១	មិនបានដឹង/ពុំមានព័ត៌មាន	សូចនាករនេះពុំមាន ឬពុំមានព័ត៌មាន
០	មិនពាក់ព័ន្ធ	សូចនាករមិនអាចប្រើការបាន ឬអ្នកផ្តល់បទសម្ភាស “មិនដឹង”។

៣. លទ្ធផលនៃការសិក្សាជាមូលដ្ឋានបែងចែកតាមសូចនាករគោល ៖ ដំណើរការយុត្តិធម៌អន្តរកាលដោយមានការផ្តើយតបយេនឌ័រក្នុងអង្គការសង្គមស៊ីវិល

ខាងក្រោមនេះគឺជាលទ្ធផលនៃការសិក្សាជាមូលដ្ឋានស្តីពីវិធីសាស្ត្រឆ្លើយតបយេនឌ័រក្នុងយុត្តិធម៌អន្តរ នៅក្នុង ក្រុមសង្គមស៊ីវិល។ អង្គការមិនមែនរដ្ឋាភិបាលនីមួយៗ ត្រូវបានដាក់ពិន្ទុផ្ទាល់ខ្លួន ដោយពិន្ទុទាំងនេះត្រូវបានយកទៅផ្ទៀងផ្ទាត់ជាមធ្យមជាមួយនឹងជាពិន្ទុសរុបរបស់អង្គការមិនមែនរដ្ឋាភិបាលទាំងអស់។ ការអង្កេតជារួម ទាក់ទងនឹងលទ្ធផលទាំងនេះ ត្រូវបានធ្វើឡើងទៅតាមសូចនាករនីមួយៗ។

ពិន្ទុទាំងនេះត្រូវបានបូកសរុបដើម្បីរកចំនួនដែលជិតបំផុត សម្រាប់ផ្ទៀងផ្ទាត់នឹងមាត្រដ្ឋានវាយតម្លៃ។ ចំនួនពិតប្រាកដមានសរសេរនៅក្នុងវង់ក្រចកខាងក្រោមសម្រាប់ពិន្ទុនីមួយៗ។

	ពិន្ទុជាមធ្យម	NGO ក	NGO ខ	NGO គ	NGO ឃ	NGO ង	NGO ច	NGO ឆ	NGO ជ	NGO ឈ	NGO ញ	NGO ដ	NGO ឋ
ក. ការបញ្ចូលកង្វល់នានារបស់ស្ត្រី និងបុរសទៅក្នុងគោលនយោបាយ និងគម្រោងទាំងអស់		๐-๕	๐-๕	๐-๕	๐-๕	๐-๕	๐-๕	๐-๕	๐-๕	๐-๕	๐-๕	๐-๕	๐-๕
๑. មានការប្រមូល និងវិភាគទិន្នន័យបែងចែកតាមភេទ ឬមានមូលហេតុជាក់លាក់ក្នុងការមិនបែងចែកទិន្នន័យតាមភេទ	**๓ (๒,๖๖)**	๑	๑	๔	๒	๓	๓	๔	๑	๒	๕	๒	๔
		ទិន្នន័យមួយចំនួនត្រូវបានបែងចែកតាមភេទ ប៉ុន្តែការបែងចែកទិន្នន័យតាមភេទមិនមានលក្ខណៈជាប្រព័ន្ធឡើយ។ អ្នកផ្តល់សម្ភាសន៍ប្រើវិធីសាស្ត្រផ្សេងៗគ្នាក្នុងការបែងចែកទិន្នន័យទាក់ទិននឹងចំនួនរបស់ស្ត្រី និងបុរស ដែលបានចូលរួមនៅក្នុងគម្រោង។ ឧទាហរណ៍ អង្គការមិនមែនរដ្ឋាភិបាលមួយរក្សាទុកទិន្នន័យមូលដ្ឋាន នៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដោយបែងចែកតាមភេទ នៅក្នុងដំណើរការនីតិវិធីរបស់ អ.វ.ត.ក។ ទោះជាយ៉ាងនោះក្តី អង្គការភាគច្រើន ដែលមិនបានប្រមូលព័ត៌មាន ឬមិនបានវិភាគព័ត៌មាននោះ ដាច់ខាតត្រូវតែយល់ឲ្យបានច្បាស់ជាងមុនអំពីអត្ថប្យោជន៍យេនឌ័រនៅក្នុងកម្មវិធីរបស់ខ្លួនទេ។ នៅក្នុងសិក្ខាសាលារបស់អង្គការមិនមែនរដ្ឋាភិបាលស្តីពីបទបង្ហាញលទ្ធផលជាមូលដ្ឋានបឋមអង្គការមិនមែនរដ្ឋាភិបាលមួយបានលើកឡើងពីសារៈសំខាន់ នៃ											

		ការរួមបញ្ចូលគ្នារវាងការរៀបចំថវិកាដើម្បីឆ្លើយតបយេនឌ័រដោយធ្វើការប្រមូល និងការវិភាគទិន្នន័យបែងចែកតាមភេទ។ វិធីសាស្ត្រទាំងពីរនេះសុទ្ធតែមានសារៈសំខាន់ក្នុងកំណត់អត្តសញ្ញាណ អ្នកទទួលផលពីកម្មវិធី កាន់តែប្រសើរឡើង និងដើម្បីត្រួតពិនិត្យការវិនិយោគក្នុងអនុវត្តការងារជាក់ស្តែងធៀបនឹងលទ្ធផលពាក់ព័ន្ធនឹងសមភាពយេនឌ័រ។											
២. ស្ត្រី និងបុរសមានឥទ្ធិពលក្នុងឋានៈជាអ្នកធ្វើសេចក្តីសម្រេចក្នុងចំណោមបុគ្គលិកយ៉ាងច្រើន (យ៉ាងតិចបំផុត ៣០%)។	**៣ (៣,១៦)**	២	៣	៣	២	៣	២	៤	៥	២	៣	៥	៤
		អ្នកផ្តល់សម្ភាសន៍ជាង ៣០% រាយការណ៍ថាមានស្ត្រីយ៉ាងតិចបំផុត ២៥% ស្ថិតនៅក្នុងមុខតំណែងជាអ្នកធ្វើសេចក្តីសម្រេចនៅក្នុងអង្គការរបស់ខ្លួន។ អង្គការច្រើនជាងមួយរាយការណ៍ថាមានគោលដៅជំរុញឲ្យមានតំណាងជាស្ត្រីចំនួន ៤០% ក្នុងតំណែងជាអ្នកធ្វើសេចក្តីសម្រេច ប៉ុន្តែអង្គការទាំងនោះមិនទាន់បានសម្រេចគោលដៅនេះនៅឡើយទេ។ ទោះបីស្ត្រីក្នុងមុខតំណែងធ្វើសេចក្តីសម្រេចមានចំនួនច្រើនគួរឲ្យកត់សម្គាល់ក៏ដោយ ក៏អ្នកផ្តល់សម្ភាសន៍មួយចំនួនរាយការណ៍ថាការស្វែងរក ស្ត្រីដែលមានសមត្ថភាពសម្រាប់មុខតំណែងខ្ពស់ៗក្នុងការធ្វើការសម្រេច នៅតែជាបញ្ហាប្រឈមដ៏ចម្បង។ បញ្ហានេះទំនងបណ្តាលមកពីការរើសអើងផ្នែកយេនឌ័រក្នុងការទទួលបានការអប់រំ ដែលជាហេតុធ្វើឲ្យស្ត្រីមានសមត្ថភាពមានចំនួនតិចតួច។ ប្រការនេះក៏ប្រហែលពាក់ព័ន្ធទៅនឹងការទទួលខុសត្រូវបន្ថែមរបស់ស្ត្រីនៅក្នុងគ្រួសារ ដែលជាផ្នែកមួយនៃតួនាទីយេនឌ័រ ព្រមទាំងកត្តារារាំងដទៃទៀត ដែលជាទូទៅស្ត្រីជួបប្រទះ ប៉ុន្តែមិនមែនជាឧបសគ្គរបស់បុរស ដូចជា ឧបសគ្គក្នុងការធ្វើដំណើរទៅធ្វើការ ឬ ទៅ ចូលរួមកិច្ចប្រជុំក្រៅម៉ោងធ្វើការជាដើម។											
ខ. សកម្មភាពជាក់លាក់មួយចំនួនត្រូវបានអនុវត្តក្នុងគោលបំណងលើកកម្ពស់ អំណាច		០-៥	០-៥	០-៥	០-៥	០-៥	០-៥	០-៥	០-៥	០-៥	០-៥	០-៥	០-៥

របស់ស្ត្រី។													
៣. យ៉ាងហោចណាស់លទ្ធផលពីកម្មវិធីមួយបញ្ជាក់យ៉ាងច្បាស់ពីវិធីលើកកម្ពស់សមភាពយេនឌ័រ និងការលើកកម្ពស់អំណាចរបស់ស្ត្រី។	**២ (២,៤១)**	១	១	១	២	៤	៤	១	៣	២	៥	១	៤
		អ្នកផ្តល់សម្ភាសន៍ចំនួន ៣0% បញ្ជាក់យ៉ាងច្បាស់ពីវិធីលើកកម្ពស់សម ភាពយេនឌ័រ និងការលើកកម្ពស់អំណាចរបស់ស្ត្រីនៅក្នុងលទ្ធផលនៃកម្ម វិធីមួយយ៉ាងតិចមួយ។ ទោះជាយ៉ាងនេះក្តី មានអ្នកផ្តល់សម្ភាសន៍តែម្នាក់ ប៉ុណ្ណោះដែលបានលើកឡើងពីវិធីនេះនៅក្នុងកម្មវិធីច្រើនជាងមួយ។ អ្នកផ្តល់សម្ភាសន៍ប្រហែល ៤0% មិនអាចកំណត់កម្មវិធីដែលបញ្ជាក់យ៉ាងច្បាស់ពីវិធីលើកកម្ពស់សមភាពយេនឌ័រ និងការលើកកម្ពស់អំណាចរបស់ស្ត្រី។ទោះជាយ៉ាងនេះក្តីអ្នកផ្តល់សម្ភាសន៍ភាគច្រើនរាយការណ៍ថាគម្រោង ឬកម្មវិធីជាច្រើនរបស់ពួកគេមានបញ្ចូលសមភាពយេនឌ័រ ហើយ ថាស្ត្រីទទួលបានការលើកទឹកចិត្តជាពិសេសដើម្បីឲ្យចូលរួមក្នុងសកម្មភាព គម្រោង។ ឧទាហរណ៍ ដើមបណ្តឹងរដ្ឋប្បវេណីជាស្ត្រី ត្រូវបានលើកទឹកចិត្តឲ្យចូលរួមវេទិកាផ្សព្វផ្សាយព័ត៌មានស្តីពីការវិវត្តរបស់ អ.វ.ត.ក ដែលបានរៀបចំឡើងដោយអង្គការមិនមែនរដ្ឋាភិបាលនៅថ្នាក់ខេត្តឬថ្នាក់តំបន់។ដើមបណ្តឹងរដ្ឋប្បវេណីជាស្ត្រី និងបុរស ទទួលបានជំនួយហិរញ្ញវត្ថុ និងជំនួយ ផ្សេងៗទៀតពីអង្គការមិនមែនរដ្ឋាភិបាល ដើម្បីជួយសម្រួលដល់ការចូលរួម ដូចជាថ្លៃធ្វើដំណើរ ថ្លៃស្នាក់នៅ និងម្ហូបអាហារក្នុងអំឡុងពេលអនុវត្តសកម្មភាព ក៏ដូចជាការណែនាំមុនពេលអនុវត្តសកម្មភាព។ អ្នកផ្តល់សម្ភាសន៍មួយចំនួនកត់សម្គាល់ថា តាមរយៈការលើកកម្ពស់អំណាចដល់ស្ត្រីឲ្យចូលរួមក្នុងកម្មវិធីទាំងនេះ ស្ត្រីទំនងជាអាចចូលរួមក្នុងសកម្មភាពសហគមន៍ដទៃទៀត និងជួយពង្រឹងលទ្ធផលកម្មវិធីជារួម។ ឧទាហរណ៍ អង្គការមិនមែនរដ្ឋាភិបាលមួយចំនួនកំពុងផ្តល់វគ្គបណ្តុះបណ្តាលដើម្បីពង្រឹងសមត្ថភាពផ្នែកដឹកនាំដល់តំណាងដើមបណ្តឹងរដ្ឋប្បវេណី ហើយស្ត្រីត្រូវបានជ្រើសរើសជាអ្នកផ្តល់ព័ត៌មាននៅថ្នាក់មូលដ្ឋាន។ កម្មវិធីផ្សេងៗទៀត ត្រូវ												

		បានអនុវត្ត ដើម្បីពង្រឹងទំនុកចិត្តស្ត្រី ក្នុងគោលដៅជួយឲ្យពួកគាត់អាចផ្តាស់ប្តូរពីស្ត្រីពោរពេញដោយភាពអៀនខ្មាស់ទៅជាស្ត្រីដែលអាចនិយាយថា “ខ្ញុំគឺជាដើមបណ្តឹងរដ្ឋប្បវេណី” និងចូលរួមក្នុងនីតិវិធីព្រហ្មទណ្ឌនៅក្នុង អ.វ.ត.ក ដើម្បីទាមទារឲ្យដាក់អតីតមេដឹកនាំខ្មែរក្រហមឲ្យទទួលខុសត្រូវចំពោះមុខច្បាប់។ តាមការអង្កេតលើអ្នកផ្តល់សម្ភាសន៍ ពួកគេដែលជាស្ត្រីជាច្រើនទំនងជាមានទំនុកចិត្ត ក្នុងការបង្ហាញ និងទាមទារតួនាទី និងបញ្ចេញយោបល់របស់ខ្លួនតាមរយៈសកម្មភាពទាំងនេះ។
៤. ភាគីពាក់ព័ន្ធ/ដៃគូ មានឥទ្ធិពល (តាមរយៈការចូលរួមដោយផ្ទាល់ ឬតាមរយៈការពិគ្រោះយោបល់) ក្នុងការរៀបចំ អនុវត្ត ត្រួតពិនិត្យ និងវាយតម្លៃកម្មវិធី។	**៣ (២,៨៣)**	៣ ២ ៣ ៤ ៤ ៣ ២ ១ ៣ ៤ ២ ៣
		អ្នកផ្តល់សម្ភាសន៍ភាគច្រើនរាយការណ៍ថា ជាទូទៅ ពួកគាត់ ទាំងបុរស និងស្ត្រី ចាំបាច់ត្រូវចូលរួមជាមួយភាគី និងដៃគូពាក់ព័ន្ធ ក្នុងការរៀបចំ អនុវត្ត ត្រួតពិនិត្យ និងវាយតម្លៃគម្រោងនានា ទោះបីការខិតខំប្រឹងប្រែង ទាំងនេះត្រូវបានធ្វើឡើងជាលក្ខណៈមិនអចិន្ត្រៃយ៍ក៏ដោយ ពោលគឺមិនមែនជាលក្ខណៈជាប្រព័ន្ធ និងជាទម្រង់ជាផ្លូវការឡើយ។ ការពិគ្រោះយោបល់ប្រចាំឆ្នាំជាមួយភាគីពាក់ព័ន្ធខាងក្នុង និងខាងក្រៅអង្គការ គឺជាវិធីងាយស្រួលក្នុងការធានាឲ្យមានការឆ្លុះបញ្ចាំងផ្ទាល់ខ្លួន និងការឆ្លើយតបនៃកម្មវិធីទាំងនេះ។ ដូចគ្នានេះដែរ អ្នកផ្តល់សម្ភាសន៍មួយចំនួន រាយការណ៍ពីការពិភាក្សាជាប្រចាំនូវ “មេរៀនជាបទពិសោធន៍” ដែលជាការទង្វើដ៏សំខាន់មួយ ប៉ុន្តែវាមិនទាន់មានលក្ខណៈច្បាស់លាស់នៅឡើយទេ ថាតើគួរចែករំលែកលទ្ធផលទាំងនេះជាមួយភាគីពាក់ព័ន្ធដែរឬទេ ឬថាតើគួរចែករំលែកលទ្ធផលទាំងនេះជាមួយភាគីពាក់ព័ន្ធតាមវិធីណា។ អ្នកផ្តល់សម្ភាសន៍ដែលកំពុងធ្វើការជាមួយដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះ ទំនងជាបានរៀបចំការពិគ្រោះយោបល់ផ្ទាក់តំបន់ និងធ្វើសហប្រតិបត្តិការជាមួយដៃគូពាក់ព័ន្ធសំខាន់ៗនៃ អ.វ.ត.ក ជាពិសេសជាមួយអង្គភាពគាំពារជនរងគ្រោះ លើបញ្ហាមួយចំនួន ដូចជា សំណង និងការចូលរួមរបស់ជនរងគ្រោះ។ នៅក្នុងដំណើរការភាគច្រើន ស្ត្រីត្រូវ

		បានអញ្ជើញឲ្យចូលរួមជាផ្នែកមួយនៃកិច្ចពិគ្រោះយោបល់ និង/ឬចូលរួមដោយផ្ទាល់។ ឧទាហរណ៍ ស្ត្រីដែលត្រូវបានចាត់ទុកថាជាអ្នកទទួលផលពីគម្រោងទាំងនេះ (ជនរងគ្រោះ/ដើមបណ្តឹងរដ្ឋប្បវេណី ដែល អ.វ.ត.ក បានទទួលស្គាល់) ត្រូវបានអញ្ជើញឲ្យចូលរួមក្នុងកិច្ចប្រជុំ និងកិច្ចពិគ្រោះ យោបល់ជាក្រុមនៅថ្នាក់សហគមន៍ ឬថ្នាក់ជាតិ ហើយសាច់រឿងក្នុងជីវិត តម្រូវការក្តីបារម្ភ និងសំណូមពររបស់ស្ត្រីទាំងនោះ ត្រូវបានដាក់បញ្ចូល ទៅក្នុងគម្រោងនានា។ ទោះជាយ៉ាងនេះក្តី អ្នកផ្តល់សម្ភាសន៍មួយចំនួននិយាយថា ស្ត្រីមិនត្រូវបានអញ្ជើញឲ្យចូលរួមក្នុងគ្រប់ ដំណាក់កាលនៃដំណើរការទាំងនោះឡើយ ដោយសារតែលទ្ធភាពចូលរួមរបស់ពួកគាត់ ពេលវេលា និងហិរញ្ញប្បទានមានកំណត់។ អ្នកផ្តល់សម្ភាសន៍មួយចំនួនមានផែនការសកម្មភាពជាក់លាក់ រួមទាំងការពិគ្រោះយោបល់យ៉ាងទៀងទាត់ជាមួយភាគីពាក់ព័ន្ធ ឬអ្នកទទួលផល និងយល់ឃើញថា ការពិគ្រោះយោបល់ជាមួយអ្នកទទួលផលធ្វើឲ្យគម្រោង ទាំងនោះសម្រេចបានលទ្ធផល និងមានប្រសិទ្ធភាពប្រសើរជាងមុន។ ប្រការសំខាន់ដែលគួរឲ្យកត់សម្គាល់នោះគឺថា ផលប្រយោជន៍នៃការបញ្ចូលភាគីពាក់ព័ន្ធទៅក្នុងដំណើរការរៀបចំ និងត្រួតពិនិត្យ គឺព័ត៌មានដែលទទួលបានពីអ្នកទទួលផលស្តីពីប្រសិទ្ធភាពនៃកម្មវិធីនៅកម្រិតសហគមន៍(វិធីសាស្ត្រវិមជ្ឈការ)។ ជាពិសេស សម្រាប់ស្ត្រីដែលទំនងជាស្ថិតក្នុងកម្រិតធ្វើសេចក្តីសម្រេចតិចជាងបុរសនៅក្នុងអង្គការ ការពិគ្រោះយោបល់ជាមួយអ្នកទទួលផលមានសារៈសំខាន់យ៉ាងខ្លាំងដើម្បីធានាឲ្យបានថា កម្មវិធីទាំងអស់ទទួលបានលទ្ធផលតាមការគ្រោងទុក។ អ្នកផ្តល់សម្ភាសន៍មួយចំនួន ទំនងជាមិនបានដឹងច្បាស់អំពីវិធីសាស្ត្រអនុវត្តដ៏ល្អ ក្នុងការពិគ្រោះយោបល់ជាមួយស្ត្រី ឬដាក់បញ្ចូលគោលគំនិតរបស់ស្ត្រីទៅក្នុងការរៀបចំ ឬត្រួតពិនិត្យគម្រោងឡើយ។ ដូច្នេះ នេះគឺជាឱកាស

		សម្រាប់ផ្តល់វគ្គបណ្តុះបណ្តាលដល់អង្គការមិនមែនរដ្ឋាភិបាល អំពីការរៀបចំត្រួតពិនិត្យនិងវាយតម្លៃគម្រោងដែលមានការចូលរួមដោយផ្អែកលើសិទ្ធិមនុស្ស											
គ. (បទដ្ឋាន)អាណត្តិផ្លូវការរបស់អង្គការត្រូវកំណត់ឧក្រិដ្ឋកម្មប្រឆាំងនឹងស្ត្រីភេទជាដើមចមនៃក្តីបារម្ភជារួម		០-៥	០-៥	០-៥	០-៥	០-៥	០-៥	០-៥	០-៥	០-៥	០-៥	០-៥	០-៥
៥. អាណត្តិរបស់អង្គការត្រូវចាត់ទុកឧក្រិដ្ឋកម្មប្រឆាំងនឹងស្ត្រីភេទជាដើមចម នៃក្តីបារម្ភជារួម។	**១ (១,៥៧)**	១	១	២	០	០	០	១	០	០	១	១	៤
		អង្គការចំនួន ៧ ប៉ុណ្ណោះ ក្នុងចំណោមអង្គការមិនមែនរដ្ឋាភិបាលទាំងអស់ដែលបានចូលរួម ត្រូវបានសួរសំណួរនេះ ដោយសារតែកំហុសឆ្គងនៅក្នុងដំណើរការសម្ភាសន៍។ អង្គការដែលមិនទាន់បានសម្ភាសន៍ចំនួន ៥ ទៀត ត្រូវបានផ្តល់ពិន្ទុ ០ ដោយសារតែគ្មានព័ត៌មាន។ តាមរយៈចម្លើយដែលអាចប្រើការបាន អង្គការតិចតួចប៉ុណ្ណោះបានចាត់ទុកឧក្រិដ្ឋកម្មប្រឆាំងនឹងស្ត្រី រួមបញ្ចូលទាំងបទពិសោធន៍ពិសេសពីការរំលោភសិទ្ធិមនុស្សថា ជាបញ្ហានៃក្តីបារម្ភដ៏ចម្បងនៃអង្គការរបស់ខ្លួន។ ទោះជាយ៉ាងនេះក្តី អង្គការភាគច្រើនទទួលស្គាល់ពីសារៈសំខាន់ក្នុងការចាត់ការរំលោភបំពានលើសិទ្ធិស្ត្រីថាជាផ្នែកចាំបាច់ក្នុងការងាររបស់ខ្លួន។										
៦. ក្របខ័ណ្ឌច្បាប់និងបទដ្ឋានអន្តរជាតិស្តីពីការរើសអើងផ្នែកយេនឌ័រ និងអំពើហិង្សាផ្លូវភេទនៅក្នុងជម្លោះ ត្រូវបានយកមកប្រើជាឯកសារ	**២ (១,៧៥)**	១	៣	១	១	១	១	២	៤	១	១	១	៤
		អ្នកផ្តល់សម្ភាសន៍ភាគច្រើននិយាយថា ពួកគាត់កម្រយកបទដ្ឋាន និងយុត្តិសាស្ត្រអន្តរជាតិជាក់លាក់ជាឯកសារយោងសម្រាប់សិទ្ធិស្ត្រីណាស់ និងថាបទដ្ឋាន និងយុត្តិសាស្ត្រអន្តរជាតិទាំងនោះ ជាញឹកញាប់មិនត្រូវបានយកមកអនុវត្តឡើយនៅក្នុងបរិបទនៃប្រទេសកម្ពុជា។ អ្នកផ្តល់សម្ភាសន៍តិចតួចប៉ុណ្ណោះ បានរាយការណ៍ថា ពួកគាត់បានយក										

យោង (CEDAW, ICTY,ICTR, SCSL, ICC, UN SCR 1325 ។ល។)		ក្របខ័ណ្ឌច្បាប់ និងបទដ្ឋានអន្តរជាតិមួយចំនួនធ្វើជាឯកសារយោងនៅក្នុងការងាររបស់ខ្លួនទាក់ទិនទៅនឹងការរើសអើងផ្នែកយេនឌ័រ និងអំពើហិង្សាផ្លូវភេទនៅក្នុងជម្លោះ។ ក្របខ័ណ្ឌច្បាប់ភាគច្រើន ត្រូវបានយកជាឯកសារយោងនៅក្នុងញត្តិ ឬសារណាផ្នែកច្បាប់ដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្នុងពេលតំណាងឲ្យក្ងនក្តីរបស់ខ្លួននៅចំពោះមុខ អ.វ.ត.ក ដោយធ្វើការពិចារណាអំពីបទដ្ឋានអន្តរជាតិនានា ដូចជា បទប្បញ្ញត្តិនៅក្នុងតុលាការឧក្រិដ្ឋកម្មអន្តរជាតិ (ICC) តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី (ICTY) ឬតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ រ៉ាន់ដា(ICTR) ឬយុត្តិសាស្ត្រផ្សេងៗទៀត។ បើទោះបីជា ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ (CEDAW) (នៅថ្ងៃ ទី ១៥ ខែ តុលា ឆ្នាំ ១៩៩២) និងពិធីសារបន្ថែមទៅនឹងអនុសញ្ញា CEDAW នេះ (នៅថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១០) ក៏ប្រទេសកម្ពុជាត្រូវអនុវត្ត អនុសញ្ញា និងពិធីសារបន្ថែមនេះ។ ទោះជាយ៉ាងនេះក្តី មានអ្នកផ្តល់សម្ភាសន៍តិចតួចប៉ុណ្ណោះ ដែលបានយកបទប្បញ្ញត្តិ ឬ មាត្រានានានៅក្នុងអនុសញ្ញា CEDAW នេះ ធ្វើជាឯកសារយោងសម្រាប់គម្រោងរបស់ខ្លួនពាក់ព័ន្ធទៅនឹងស្ត្រី និងការលើកកម្ពស់ និងការការពារយេនឌ័រ។ ក្នុងពេលសម្ភាសន៍ អ្នកផ្តល់សម្ភាសន៍ម្នាក់បានបង្ហាញពីបំណងនៃការកំណត់ឱកាសបើកវគ្គបណ្តុះបណ្តាលសម្រាប់បុគ្គលិកស្តីពីលិខិតតុបករណ៍ អន្តរជាតិដែលមានចែងនូវបទប្បញ្ញត្តិជាក់លាក់ស្តីពីយេនឌ័រ ឬ ឧក្រិដ្ឋកម្មផ្លូវភេទសម្រាប់ជាមធ្យោបាយដើម្បីលើកកម្ពស់ការតស៊ូមតិ និងយន្តការទទួលខុសត្រូវជាសកល។											
៧. ការធ្វើវៀបចំទិន្នន័យ	**១**	១	១	១	១	១	១	២	១	២	១	២	៣

ជម្លោះ បានកត់ត្រានូវអំពើហិង្សាផ្សេងៗ ដែលស្ត្រីជួបប្រទះ និងផលប៉ះពាល់នៃអំពើហិង្សា និងកត្តាពាក់ព័ន្ធដទៃទៀត។	(១,៤១)	អ្នកផ្តល់សម្ភាសន៍មិនធ្វើការរៀបចំទិន្នន័យជម្លោះទេដែលអ្នកផ្តល់សម្ភាសន៍ភាគច្រើនបានរាយការណ៍ថា ពួកគាត់យល់ឃើញថា ការរៀបចំទិន្នន័យជម្លោះនេះមិនមែនជាតួនាទីសមស្របរបស់អង្គការមិនមែនរដ្ឋាភិបាល ឡើយ។ ផ្ទុយទៅវិញទៀត អង្គការមិនមែនរដ្ឋាភិបាលជាច្រើនយល់ឃើញ ថា អ.រ.ត.ក គឺជាស្ថាប័នដែលមានអំណាច និងសមត្ថកិច្ចក្នុងវិស័យនេះ។ ការរៀបចំទិន្នន័យទាក់ទងនឹងការយល់ដឹងយេនឌ័ររអាចផ្តល់ទិន្នន័យពេញលេញទាក់ទងនឹងបទពិសេសបុរស និងស្ត្រីដែលបានឆ្លងកាត់ជម្លោះ ក្នុងនោះឧក្រិដ្ឋនានា និងឧក្រិដ្ឋដូចគ្នា ប៉ុន្តែបង្កផលប៉ះពាល់ផ្សេង។ ការស្រាវជ្រាវបង្ហាញថា ស្ត្រីដែលជាជនរងគ្រោះក្នុងជម្លោះ ជាញឹកញាប់ត្រូវបានមើល រំលងដូច្នេះហើយបទពិសោធន៍ទាំងនោះមិនត្រូវបានកំណត់ឲ្យបានច្បាស់លាស់ឡើយទេ នៅក្នុងការរៀបចំ និងការអនុវត្តគម្រោង ដែលធ្វើឲ្យមានឥទ្ធិពលដល់លទ្ធផលចុងក្រោយ។ ប្រការគួរឲ្យកត់សម្គាល់នោះគឺថា អ្នកផ្តល់សម្ភាសន៍មួយចំនួនបានខិតខំប្រឹងប្រែងរៀបចំពាក្យបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលពួកគាត់បានទទួល និងបានបែងចែកប្រភេទនៃអ្នកដាក់ពាក្យ។ ដោយសារអ្នកដាក់ពាក្យសុំពិពណ៌នាអំពីបទពិសោធន៍របស់ខ្លួនក្នុងរបបខ្មែរក្រហមនៅពេលបំពេញពាក្យស្នើសុំនោះទើបនៅពេលគេអាចរកឯកសារដើមសម្រាប់ ចងក្រងជាទិន្នន័យ។ ទោះជាយ៉ាងនេះក្តី ការប្រើប្រាស់ ឯកសារនេះ ត្រូវមានការបំពេញទម្រង់នៃព្រមព្រៀងពីបំណងនៃការប្រើប្រាស់ព័ត៌មាន និង បទដ្ឋានរក្សាការសម្ងាត់សម្រាប់វិធីសាស្ត្រស្រាវជ្រាវអំពីមនុស្សជាតិ។ អ្នកផ្តល់សម្ភាសន៍មួយចំនួន បានរាយការណ៍ថា ទោះបីមិនមានការរៀបចំទិន្នន័យជាក់លាក់ក៏ដោយ ក៏ពាក្យសុំដែលបានដាក់ដោយអ្នកដាក់ពាក្យសុំជាស្ត្រី ច្រើនតែពិពណ៌នាពីទុក្ខលំបាកនៃការប៉ះពាល់ផ្លូវចិត្តរ៉ាំរ៉ៃ។

ឃ. (នីតិវិធី) ជំហានសមស្រប ត្រូវបានអនុវត្តដើម្បីលុបបំបាត់ឧបសគ្គ ជាក់ស្តែង ដែលស្ត្រីអាចនឹងប្រឈមក្នុងការទទួលបានយុត្តិធម៌អន្តរកាល។		០-៥	០-៥	០-៥	០-៥	០-៥	០-៥	០-៥	០-៥	០-៥	០-៥	០-៥	០-៥
	២ (១,៥)	ពិន្ទុសរុប											
៨. សមត្ថកិច្ច និងជំនាញផ្នែកយេនឌ័រត្រូវបានលើកកម្ពស់ និងទទួលបានការគាំទ្រ។		១	១	១	១	១	១	១	៤	១	១	២	៣
		ពិន្ទុតាមចំណុចនីមួយៗ											
៨.ក. ទីប្រឹក្សាដែលមានជំនាញផ្នែកច្បាប់ទាក់ទងនឹងអំពើហិង្សាផ្លូវភេទ និងយេនឌ័រ (SGBV) នៅក្នុងជម្ពោះ។		១ ១	១ ១	១ ១	១ ១	១ ១	១ ១	២ ១	៥ ៥	១ ១	១ ១	៣ ២	៣ ៣
		១ ១	១ ១	១ ១	១ ១	១ ១	១ ១	១ ១	២ ២	២ ១	៤ ១	១ ១	៣ ១
៨.ខ. ទីប្រឹក្សាដែលមានជំនាញផ្នែកអំពើហិង្សាផ្លូវភេទ និងយេនឌ័រ (SGBV) និងវិធីសាស្ត្រប្រមូលភស្តុតាងដែលពាក់ព័ន្ធនឹងការទទួលរងគ្រោះខាងយេនឌ័រ។		អ្នកផ្តល់សម្ភាសន៍មួយចំនួនតូចប៉ុណ្ណោះ មានទីប្រឹក្សា ឬបុគ្គលិកជំនាញ ដែលមានជំនាញផ្នែកច្បាប់ទាក់ទងនឹងអំពើហិង្សាផ្លូវភេទ និងយេនឌ័រ នៅក្នុងជម្ពោះ ឬវិធីសាស្ត្រពាក់ព័ន្ធនឹងការយល់ដឹងពីយេនឌ័រ។ មានទីប្រឹក្សាជាស្ត្រីចំនួនតិចតួចប៉ុណ្ណោះ ដែលបានធ្វើការជាមួយបុគ្គលិកបង្គោលរបស់គម្រោង ដើម្បីរៀបចំសកម្មភាពពាក់ព័ន្ធនឹងយេនឌ័រសម្រាប់គម្រោងទាំងនេះ។ ជាញឹកញាប់ណាស់ អ្នកផ្តល់បទសម្ភាសន៍យល់ឃើញថា ការអនុវត្តគម្រោងគួរស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ទីប្រឹក្សារួមម្នាក់។										

៨.គ. បុគ្គលិកដែលមានបទពិសោធន៍ផ្នែកជំងឺបាក់ទឹកចិត្ត ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មផ្លូវភេទ។		មេធាវីអន្តរជាតិម្នាក់ ដែលបាន និងកំពុងធ្វើការយ៉ាងជិតដិតជាមួយនឹងអង្គ ការមិនមែនរដ្ឋាភិបាលមួយចំនួនដែលធ្វើការងារលើផ្នែកនេះករណីនេះមានជំនាញការងារយេនឌ័រ ប៉ុន្តែជាញឹកញាប់ គាត់ជាប់រវល់នឹងការងារតំណាងឲ្យកូនក្តីរបស់គាត់នៅចំពោះមុខអ.វ.ត.ក។
៨.ឃ. បុគ្គលិកបង្គោលផ្នែកយេនឌ័រត្រូវបានចាត់តាំងឲ្យរៀបចំវគ្គបណ្តុះបណ្តាលស្តីពីយេនឌ័រតាមអង្គការ។		នៅកម្រិតអនុវត្តគម្រោង បុគ្គលិកមួយចំនួនតូចប៉ុណ្ណោះមានជំនាញដោះស្រាយបញ្ហាទាក់ទិននឹងជម្ងឺបាក់ទឹកចិត្ត ឬឧក្រិដ្ឋកម្មពាក់ព័ន្ធនឹងផ្លូវភេទ ផ្សេងៗទៀត ប៉ុន្តែមិនមានជំនាញផ្តល់ប្រឹក្សានោះឡើយ។ អ្វីដែលជាការរំពឹងនោះគឺថាបុគ្គលិកដែលត្រូវបានជ្រើសរើសឲ្យបំពេញការងារពាក់ព័ន្ធ នឹងជម្ងឺបាក់ទឹកចិត្ត ឬគម្រោងពាក់ព័ន្ធនឹងយេនឌ័រ អាចនឹងមានចំណេះដឹងទាក់ទងនឹងជម្ងឺបាក់ទឹកចិត្ត និងបញ្ហាយេនឌ័រ។ អ្នកផ្តល់សម្ភាសន៍ស្ទើរតែទាំងអស់និយាយថា អង្គការរបស់ខ្លួនពុំមានបុគ្គលិកបង្គោលផ្នែកយេនឌ័រសម្រាប់រៀបចំវគ្គបណ្តុះបណ្តាលចាំបាច់ស្តីពី យេនឌ័រទេ។ អ្នកផ្តល់សម្ភាសន៍ចំនួន ១0% ប៉ុណ្ណោះ បញ្ជាក់ថា ពួកគាត់មានទីប្រឹក្សាអន្តរជាតិម្នាក់ ដែលមានចំណេះដឹងទូទៅផ្នែកអំពើហិង្សាផ្លូវភេទ និងយេនឌ័រ និងកំពុងធ្វើការជាមួយក្រុមការងាររបស់គម្រោង ដើម្បីជួយដល់ជនរងគ្រោះដោយសារអំពើហិង្សាយេនឌ័រ។អង្គការមិនមែនរដ្ឋាភិបាលដែលខ្វះខាតបុគ្គលិកជំនាញផ្នែកនេះ គឺត្រូវពឹងផ្អែកទាំងស្រុងលើអង្គការមិនមែនរដ្ឋាភិបាលផ្សេងទៀតដែលមានជំនាញផ្នែកនេះដូចជា អង្គការ TPO និង CDP។
៩. ឧបសគ្គដែលរារាំងស្ត្រីមិនឲ្យទទួលបានយុត្តិធម៌អន្តរកាលត្រូវបានដោះស្រាយតាមរយៈការផ្តល់សេវាថែទាំកុមារ	**២ (២,១៦)**	៣ ៣ ៣ ១ ៣ ២ ១ ១ ២ ៤ ២ ១
		អង្គការមិនមែនរដ្ឋាភិបាលមួយចំនួនបានសម្របសម្រួលដល់លទ្ធភាពចូលរួមក្នុងដំណើរ យុត្តិធម៌អន្តរកាល។ ជាទូទៅ អង្គការទាំងនេះបានខិតខំប្រឹងប្រែងយ៉ាងខ្លាំង ដើម្បីបំពេញតម្រូវការជាក់លាក់របស់អ្នកចូលរួមជាស្ត្រី។ កិច្ចខិតខំប្រឹងប្រែងដើម្បីជួយឲ្យស្ត្រីចូលរួម មានដូចជា ការគាំទ្រ ដល់

ការដឹកជញ្ជូនប្រកបដោយសុវត្ថិភាព និងការបកប្រែភាសា។		ស្ត្រីតាមរយៈការនាំយកអ្នកលើកទឹកចិត្តមកជាមួយ (ជារឿយៗ គឺជាសមាជិកគ្រួសារ) នៅពេលចូលរួមក្នុងព្រឹត្តិការណ៍ផ្សេងៗ ដើម្បីជួយឲ្យស្ត្រីទាំងនោះបានចូលរួមក្នុងសកម្មភាពនានាឲ្យបានពេញលេញ ហើយនៅពេលមានថវិកាគ្រប់គ្រាន់ ស្ត្រីទទួលបានប្រាក់ឧបត្ថម្ភសម្រាប់ការធ្វើដំណើរស្នាក់នៅ និងចំណាយផ្សេងៗទៀតទាក់ទិននឹងការចូលរួមព្រឹត្តិការណ៍ ទាំង នេះជាពិសេសការចូលរួមក្នុងដំណើរការនីវិតិធីនៅ អ.វ.ត.ក នៅទីក្រុងភ្នំពេញ។ ឧទាហរណ៍មួយផ្សេងទៀត នៅពេលស្ត្រីមិនអាចធ្វើសេចក្តីសម្រេច ឬមិនអាចនិយាយប្រាប់រឿងរ៉ាវរបស់ខ្លួនប្រាប់បុគ្គលិកយកបទសម្ភាស (ជាពិសេសនៅពេលបុគ្គលិកទាំងនោះសម្ភាស ឬប្រមូលព័ត៌មានពីពួកគាត់) ការយកចិត្តទុកដាក់ ឬវិធានការពិសេស ត្រូវបានអនុវត្ត ដូចជា ការនិយាយជាមួយ និងពន្យល់ប្តីរបស់គាត់អំពីគោលបំណងនៃកិច្ចប្រជុំ និងលទ្ធភាពនៃការចូលរួមរបស់ស្ត្រីទាំងនោះនៅក្នុងដំណើរការរបស់តុលាការ។
១០. អ្នកទទួលផលទទួលបានការគាំទ្រចិត្តសង្គមមុនពេល ក្នុងអំឡុងពេល និងបន្ទាប់ពីការចូលរួម និងទទួលបានការពិគ្រោះយោបល់ស្តីពីយន្តការដោះស្រាយ ប្រតិកម្មប្រឆាំង និងការបដិសេធពីគ្រួសារ។	៣ (២, ៨១)	២ ២ ១ ៣ ៣ ៣ ២ ០ ៣ ៤ ៤ ៤		
		អង្គការមិនមែនរដ្ឋាភិបាលរាយការណ៍ថា ការគាំទ្រចិត្តសង្គមត្រូវបានផ្តល់ឲ្យអ្នកទទួលផលនៅក្នុងគ្រប់សកម្មភាពទាំងអស់។ ទោះជាយ៉ាងនោះក្តី អង្គការមិនមែនរដ្ឋាភិបាលភាគច្រើនបញ្ជូនអ្នកទទួលផលរបស់ខ្លួនទៅអង្គការ TPO ពីព្រោះអង្គការនេះ គឺជាអង្គការតែមួយប៉ុណ្ណោះ ដែលផ្តល់ការប្រឹក្សាប្រកបដោយវិជ្ជាជីវៈ។ អង្គការ TPO មានកិច្ចព្រមព្រៀងផ្តាច់មុខជាមួយ អ.វ.ត.ក ក្នុងការផ្តល់អ្នកជំនាញ និងការគាំទ្រចិត្តសង្គមដល់តុលាការ។ ជាទូទៅ មុនពេល ក្នុងអំឡុងពេល និងបន្ទាប់ពីការចូលរួមក្នុងដំណើរការនីតិវិធីនីមួយៗ បុគ្គលិករបស់អង្គការ TPO ផ្តល់ជូន ជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណីនូវបទបង្ហាញសង្ខេបស្តីពីវិធីដ៏ប្រសើរបំផុតក្នុងការគ្រប់គ្រងជម្ងឺបាក់ទឹកចិត្តរបស់ខ្លួន ព្រមទាំងផ្តល់ការគាំទ្រនៅនឹងកន្លែងជាក់ស្តែងតែម្តង។ អ្នកផ្តល់សម្ភាសន៍បានដឹងថា ពួកគាត់មិនគួរពឹងផ្អែកទាំងស្រុងទៅលើអង្គការ TPO ឡើយ ពីព្រោះនៅពេលគ្មានសមត្ថភាព	

		នៅក្នុងអង្គការរបស់ខ្លួនផ្ទាល់ ក៏ការគាំទ្រនេះក៏គ្មាននិរន្តរភាព និងប្រព័ន្ធច្បាស់លាស់ឡើយ។ ទោះជាយ៉ាងនេះក្តី បញ្ហាខ្វះធនធាន គឺជា ឧបសគ្គដែលរារាំងដល់កិច្ចខិតខំប្រឹងប្រែងរបស់ពួកគេ ក្នុងការកសាង សមត្ថភាពនៅក្នុងវិស័យនេះ។ ជាងនេះទៀត អ្នកផ្តល់សម្ភាសន៍មួយចំនួនតូចនិយាយថា អង្គការរបស់ខ្លួនមានបុគ្គលិកសម្រាប់ទំនាក់ទំនងទូទាំងប្រទេសកម្ពុជា ដែលអាចជួយឲ្យ អ្នកចូលរួមទទួលបានសេវានានា ដែលពួកគេអាចត្រូវការបន្ទាប់ពីការចូលរួម ក្នុងកម្មវិធី។ អង្គការមិនមែនរដ្ឋាភិបាលភាគច្រើន បង្ហាញពីក្តីបារម្ភអំពីលទ្ធភាពដែលជនរងគ្រោះអាចប្រឈមនឹងជំងឺបាក់ទឹកចិត្តច្រើនជាងមុន ឬកំពុងជួបប្រទះនឹងប្រតិកម្មប្រឆាំង នៅពេលដែលអង្គការមិនមែនរដ្ឋាភិបាលបានបញ្ចប់ការងាររបស់ខ្លួន។ ទោះជាយ៉ាងនេះក្តី អង្គការចំនួនតូចប៉ុណ្ណោះដែលបានរៀបចំយន្តការទុកជាមុន ដើម្បីកាត់បន្ថយហានិភ័យ ដល់កូនក្តីរបស់ខ្លួន។

១១.អ្នកទទួលផលត្រូវបានការពារពីការរើសអើងនិងប្រតិកម្មតាមរយៈការរក្សាការសម្ងាត់ និងការផ្តល់សុវត្ថិភាព រួមទាំងការតាមដានត្រួតពិនិត្យដើម្បីបំពេញតាមតម្រូវការការពារពីការគម្រាមកំហែងនៃអំពើហិង្សា ឬការសងសឹកដទៃទៀតដោយសារតែការចូល	**៣ (២,៨១)**	២	៣	១	៤	៣	៣	២	០	៣	៤	៣	៣
		អ្នកផ្តល់សម្ភាសន៍ជាច្រើន គូសបញ្ជាក់ពីភាពចាំបាច់ក្នុងការផ្តល់ការការពារ ការរក្សាការសម្ងាត់ និងសុវត្ថិភាព ប៉ុន្តែជាញឹកញាប់ណាស់ វិធានការនេះត្រូវបានផ្តល់ឲ្យជាលក្ខណៈពិសេស។ ការរក្សាការសម្ងាត់ជាអទិភាព ត្រូវបានមើលឃើញថា បានកើតមានក្នុងការអនុវត្តច្រើនជាងគេបំផុត បើប្រៀបធៀបនឹងការធានាសុវត្ថិភាព និងវិធានការការពារ។ អ្នកផ្តល់ចម្លើយភាគច្រើនរាយការណ៍ថា ការរក្សាការសម្ងាត់គឺជាផ្នែកមួយនៃក្រមសីលធម៌វិជ្ជាជីវៈទូទៅរបស់បុគ្គលិក។ ឧទាហរណ៍ នៅពេលពុំមានការរក្សាការសម្ងាត់ទៅក្នុងគោលនយោបាយផ្ទៃក្នុងជាធរមានវិញ មានសេចក្តីរាយការណ៍ថាការរក្សាការសម្ងាត់ និងការផ្តល់សុវត្ថិភាព ត្រូវបានបញ្ចូលទៅក្នុងគម្រោងគោលគំនិតនៃកម្មវិធី។										

រួមទាំងនេះ។		ម្យ៉ាងវិញទៀត អ្នកផ្តល់សម្ភាសន៍ភាគច្រើនបញ្ជាក់ថា អ្នកដាក់ពាក្យសុំ/ដើមបណ្តឹងរដ្ឋប្បវេណីទាំងស្ត្រី និងបុរស ត្រូវការវិធានការការពារ ឬវិធានការពិសេសនៅនឹងកន្លែងក្នុងពេលចូលរួមក្នុងការជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌរបស់ អ.វ.ត.ក។ យោងតាមបទបញ្ជាផ្ទៃក្នុងរបស់អ.វ.ត.ក ដើមបណ្តឹងរដ្ឋប្បវេណីតាមរយៈមេធាវីរបស់ខ្លួន អាចដាក់សំណើទៅ តុលាការ ដើម្បីស្នើសុំវិធានការការពារ។ បន្ទាប់មក តុលាការ ជាពិសេសអង្គភាពគាំពារសាក្សី និងអ្នកជំនាញ (WESU) នឹងពិចារណា សំណើនោះ ដែលអាចនឹងបញ្ជូលវិធានការការពារផ្សេងៗទៀត។ ទោះជា យ៉ាងនេះក្តី អ្នកផ្តល់សម្ភាសន៍ ជាទូទៅគិតថា នៅពេលពួកគាត់បញ្ជូន សំណុំរឿងទៅ តុលាការពួកគាត់អាចទុកសំណើនោះឲ្យអង្គភាពគាំពារ សាក្សី និងអ្នកជំនាញ ផ្តល់ការគាំទ្រប្រភេទនេះ។ នៅក្នុងករណីដូចនេះ ប្រការសំខាន់ត្រូវកត់ចំណាំគឺថា ដើមបណ្តឹងរដ្ឋប្បវេណីគ្រប់រូប នឹងទទួល បានវិធានការណ៍ដែលពួកគាត់ស្នើសុំ ពីព្រោះ អ.វ.ត.ក ជាអ្នកសម្រេចពី អ្នក ដែលមានសិទ្ធិទទួលបានសេវានេះ ដោយផ្អែកលើតម្រូវការដ៏តឹងរ៉ឹងដែលមានចែងនៅក្នុងបទបញ្ជាផ្ទៃក្នុង។ ការតាមដានត្រួតពិនិត្យ ត្រូវបានផ្តល់ជូនតាមករណីនីមួយៗ។ ជាងនេះទៀត ដូចដែលបានរៀបរាប់នៅផ្នែកខាងលើ អង្គការមិនមែនរដ្ឋាភិបាលមួយចំនួនតូចបានរៀបចំឲ្យមានបុគ្គលិកបង្គោលនៅតាមភូមិ ដែលអ្នកទទួលផលអាចពិគ្រោះយោបល់មុនពេល និងបន្ទាប់ពីការចែករំលែកបទពិសោធដល់អ្នកដទៃ។ ទោះជាយ៉ាងនេះក្តី គ្មានអ្នកផ្តល់សម្ភាសន៍ណាម្នាក់មានវិធីសាស្ត្រជាប្រព័ន្ធ ដើម្បីធានាឲ្យមានការការពារជាប្រចាំដល់ស្ត្រីដែលទៅចូលរួមក្នុងតុលាការឡើយ។ ហានិភ័យនៃប្រតិកម្មប្រឆាំង និងការបដិសេធពីសង្គមដែលអ្នកចូលរួមអាចនឹងប្រឈមនោះ ត្រូវដោះស្រាយជាលក្ខណៈប្រព័ន្ធ និងដោយសហការណ៍ គ្នាក្នុងចំណោមដៃគូចម្រុះដែលធ្វើការជាមួយជនរងគ្រោះនៃរបបខ្មែរក្រហម។

ង. (វប្បធម៌/ឥរិយាបថ) កិច្ចខិតខំប្រឹងប្រែង ត្រូវបានធ្វើឡើងដើម្បីដោះស្រាយបញ្ហាលម្អៀងយេនឌ័រនៅក្នុងស្តាប់ធនោះផ្តាល់ និងដើម្បីដោះស្រាយឥរិយាបថសង្គមអំពីការរើសអើងខាងយេនឌ័រ និងសមភាពរបស់ស្ត្រី។		០-៥	០-៥	០-៥	០-៥	០-៥	០-៥	០-៥	០-៥	០-៥	០-៥	០-៥	០-៥
១២. ស្ត្រីមានតំណាងស្មើនឹងបុរសនៅក្នុងគ្រប់ទិដ្ឋភាពទាំងអស់នៃអង្គការ (ដូចជា អ្នកស៊ើបអង្កេត អ្នកធ្វើកំណត់ហេតុ អ្នកបកប្រែ បុគ្គលិកកម្មវិធី និងបុគ្គលិកទទួលបន្ទុកការងារផ្សព្វផ្សាយ ។ល។	៣ (៣, ០៨)	៤	៤	៤	២	៣	៣	៤	៣	៣	៣	៣	១
		អ្នកផ្តល់សម្ភាសន៍ភាគច្រើនបានប្តេជ្ញាឲ្យមានស្ត្រីចំនួន ៣០ ឬ ៤០ ភាគ រយនៅក្នុងអង្គការរបស់ខ្លួន។ នៅពេលប្រៀបធៀបជាមួយសូចនាករ ២ ដែលផ្តោតលើតំណាងរបស់ស្ត្រីនៅក្នុងតួនាទីធ្វើការសម្រេចលទ្ធផលបង្ហាញ ថាជាទូទៅ ក្នុងចំណោមអ្នកផ្តល់សម្ភាសន៍របស់អង្គការមិនមែនរដ្ឋាភិបាល ស្ត្រីក្នុងតួនាទីជាបុគ្គលិកទូទៅមានភាគរយច្រើនជាងក្នុងតួនាទីជាអ្នកធ្វើការសម្រេច។ ការនេះបង្ហាញថា ឧបសគ្គអាចកើតមាននៅនឹងកន្លែងដែលធ្វើឲ្យស្ត្រីមានការលំបាកក្នុងការទទួលបានតួនាទីជាអ្នកធ្វើការសម្រេច។ ជាមួយនេះដែរ អ្នកផ្តល់សម្ភាសន៍ភាគច្រើនរាយការណ៍ថា អ្នកគ្រប់គ្រងគម្រោងភាគច្រើននៅក្នុងការិយាល័យរបស់ពួកគេគឺជាបុរស ដោយមានជំនួយការជាស្ត្រី។ អង្គការមិនមែនរដ្ឋាភិបាលច្រើនបំផុត (ប្រហែល ៨០% នៃអ្នកផ្តល់សម្ភាសន៍) រាយការណ៍ថាបានដាក់បញ្ចូលតុល្យភាពយេនឌ័រទៅក្នុងគោលនយោបាយជាលាយលក្ខណ៍អក្សរ រួមបញ្ចូលទាំងឯកសារយោងនៃការលើកកម្ពស់អំណាចរបស់បុគ្គលិកជាស្ត្រីនិងការលើកកម្ពស់នៃការបញ្ជ្រាប យេនឌ័រនៅក្នុងអង្គការ និងកម្មវិធីរបស់ខ្លួន។											

		អ្នកផ្តល់សម្ភាសន៍ទាំងអស់មានបំណងចង់ឲ្យមានបុគ្គលិកជាស្ត្រីពី ៣០% ទៅ ៤០% នៅក្នុងអង្គការរបស់ខ្លួន ប៉ុន្តែពួកគេរាយការណ៍ថា គោលដៅ នេះគឺលំបាកនឹងសម្រេចបានណាស់។ អ្នកផ្តល់សម្ភាសន៍ជឿជាក់ថា ប្រការនេះគឺដោយសារតែតួនាទីទាំងនោះភាគច្រើនតម្រូវឲ្យមានការធ្វើដំណើរជាញឹកញាប់ ដែលការនេះគឺជាការពិបាករបស់ស្ត្រីដោយសារតែការទទួលខុសត្រូវក្នុងគ្រួសារ។ អ្នកផ្តល់សម្ភាសន៍បាននិយាយថា អង្គការខ្លួនបានព្យាយាមបង្កើតយុទ្ធសាស្ត្រមួយចំនួនដើម្បីដោះស្រាយបញ្ហានេះ រួមមានការផ្តោតលើការបន្ថែមតំណាងរបស់ស្ត្រីនៅក្នុងតួនាទីជាក់លាក់ដែលមិនតម្រូវឲ្យមានការធ្វើដំណើរ ឬមានឧបសគ្គតិចជាងមុន។ ទោះជាយ៉ាងនេះក្តី វិធីសាស្ត្រនេះអាចជាការលំបាក ពីព្រោះវាអាចរារាំងអង្គការពីការកំណត់ និងឆ្លើយតបចំពោះឧបសគ្គដែលទប់ស្កាត់ស្ត្រីពីការទទួលបានការងារនៅក្នុងវិស័យផ្សេងទៀតក្នុងអង្គការ។ អ្នកផ្តល់សម្ភាសន៍ទាំងអស់ដឹងពីតម្រូវការបង្កើនចំនួនស្ត្រីនៅក្នុងអង្គការរបស់ខ្លួន ប៉ុន្តែពួកគេមិនអាចដោះស្រាយឧបសគ្គទាំងនោះ និងសម្រេចបានគោលដៅរបស់ខ្លួននៅឡើយ។											
១៣. វគ្គបណ្តុះបណ្តាលយេនឌ័រ ត្រូវបានផ្តល់ជូនបុគ្គលិកគ្រប់រូបដោយផ្អែកលើអាណត្តិ និងអំណោយផលពេលវេលា) (ក្នុងអង្គការ)។	**២ (១,៨៣)**	៣	៣	៣	១	១	១	១	៣	១	៣	១	១
		អ្នកផ្តល់សម្ភាសន៍ប្រហែល ៨០% និយាយថា អង្គការរបស់ខ្លួនមិនបាន ផ្តល់កម្មវិធីវគ្គបណ្តុះបណ្តាលជាក់លាក់ស្តីពីយេនឌ័រដល់បុគ្គលិកឬនិយោជិករបស់ខ្លួនឡើយ។ ប៉ុន្តែបុគ្គលិករបស់ពួកគាត់ តែងតែទទួលបានការអនុញ្ញាតឲ្យទៅចូលរួមវគ្គបណ្តុះបណ្តាលយេនឌ័រដែលផ្តល់ដោយភាគីទីបី។ អ្នកផ្តល់សម្ភាសន៍ជាច្រើនដែលមានការងារមិនផ្តោតទាំងស្រុងលើយេនឌ័រ ផ្តល់ហេតុផលថា វគ្គបណ្តុះបណ្តាលយេនឌ័រ គឺមិនមែនជាអាទិភាពសម្រាប់វគ្គបណ្តុះបណ្តាលបុគ្គលិកក្នុងអង្គការឡើយ។ប្រធានបទវគ្គបណ្តុះ បណ្តាលនៅ											

		ក្នុងអង្គការភាគច្រើន ត្រូវបានសម្រេចជ្រើសរើសដោយផ្អែក លើតម្រូវការរបស់បុគ្គលិក។ ទោះបីអ្នកផ្តល់បទសម្ភាសន៍បង្ហាញពីចំណាប់អារម្មណ៍ក្នុងការបើកវគ្គបណ្តុះបណ្តាល ឬការកសាងសមត្ថភាពសម្រាប់បុគ្គលិករបស់ខ្លួនស្តីពីបញ្ហាយេនឌ័រក៏ដោយ ក៏វគ្គបណ្តុះបណ្តាលយេនឌ័រជាទៀងទាត់ មិនមែនជាអាទិភាពរបស់ខ្លួនឡើយ។អ្នកផ្តល់សម្ភាសន៍មួយចំនួនទាញហេតុផលថាវគ្គបណ្តុះបណ្តាលស្តីពីយេនឌ័រ មិនត្រូវបានគេរៀបចំធ្វើឡើង ឬមិនមែនជាការចាំបាច់ដោយពួកគាត់អះអាងថា ពួកគាត់មិនមានអាណត្តិត្រូវធ្វើដូច្នេះឡើយ។
១៤. អង្គការប្រកាសឱ្យប្រើ អនុវត្ត និងកត់ត្រាសកម្មភាពនៃគោលនយោបាយដាច់ខាតចំពោះការបៀតបៀនផ្លូវភេទនៅកន្លែងធ្វើការ ដែលបុគ្គលិកបានដឹង។	**២ (១,៦៦)**	២ ៤ ១ ១ ១ ១ ១ ១ ១ ៤ ១ ២
		អ្នកផ្តល់សម្ភាសន៍តិចជាង ២០% រាយការណ៍ថាមានគោលនយោបាយច្បាស់លាស់ ដែលមិនអត់អោនឱ្យជាដាច់ខាតចំពោះការបៀតបៀនផ្លូវភេទនៅក្នុងកន្លែងធ្វើការ។ ទោះជាយ៉ាងនេះក្តី អ្នកផ្តល់សម្ភាសន៍បង្ហាញយ៉ាងច្បាស់ថាបញ្ហានៃការបៀតបៀនផ្លូវភេទត្រូវបានហាមឃាត់ក្នុងក្រមសីលធម៌និងទទួលស្គាល់ថាជាបទល្មើសដែលត្រូវផ្តន្ទាទោសតាមច្បាប់ក្នុងប្រទេស ប្រសិនបើរកឃើញពិរុទ្ធភាព។ ដោយយោងលើអ្នកផ្តល់សម្ភាសន៍ វិធីក្នុងការកំណត់បទល្មើសតូចតាច គឺការដាក់ទណ្ឌកម្មដោយអង្គការតាមរយៈការបណ្តេញចេញពីការងារភ្លាមៗ ឬការបញ្ឈប់ការងារ។ អ្នកផ្តល់សម្ភាសន៍ទាំងនោះគិតថា ការរំលោភបំពាន់ធ្ងន់ធ្ងរគួរត្រូវបានដាក់ទណ្ឌកម្ម ដោយតុលាការក្នុងស្រុក ទោះជាយ៉ាងនេះក្តី វាមិនច្បាស់ទេថាតើមានការអនុវត្តន៍ជាក់ស្តែង ឬក៏អត់។ អង្គការមិនមែនរដ្ឋាភិបាលមួយចំនួន បង្ហាញបទពិសោធន៍ល្អបំផុតនៅក្នុងលក្ខខណ្ឌគោលនយោបាយច្បាស់លាស់ ពាក្យបណ្តឹង និងយន្តការដាក់ឱ្យអនុវត្តនិងទណ្ឌកម្មជាមួយនឹងការយល់ដឹងពីបុគ្គលិកស្តីពីគោលនយោបាយ

		ទាំងនេះ។ អង្គការមិនមែនរដ្ឋាភិបាលទាំងនេះ អាចចូលរួមចំណែកយ៉ាង ច្រើន តាមរយៈការចែករំលែកគោលនយោបាយ និងកម្មវិធីមិត្តសិក្សាពីមិត្តភក្តិ ដល់អង្គការដទៃទៀតក្នុងតម្រូវការបង្កើតគោលនយោបាយ។

IV. សេចក្តីសន្និដ្ឋាន

១. ការផ្សព្វផ្សាយយេនឌ័រ

បុគ្គលិកអង្គការក្រៅរដ្ឋាភិបាលភាគច្រើនបំផុតដែលបានផ្តល់បទសម្ភាសន៍បានផ្តល់ទឡ្ហីករណ៍ថា បញ្ហាយេនឌ័រមិនបានពាក់ព័ន្ធទៅនឹងអង្គការរបស់ខ្លួនទេ ពីព្រោះអាណត្តិការងាររបស់គេ គឺត្រូវធ្វើការស្មើភាពគ្នាជាមួយអ្នកទទួលផលរបស់ខ្លួនទាំងបុរស ទាំងស្ត្រី។ ទស្សនៈវិស័យដែលបានបង្កើតឡើងនោះគឺថា មានតែអង្គការក្រៅរដ្ឋាភិបាលដែលមានអាណត្តិធ្វើការលើបញ្ហាយេនឌ័រប៉ុណ្ណោះ ត្រូវយកចិត្តទុកដាក់លើការងារយេនឌ័រ។ នេះបង្ហាញថា អង្គការមិនមែនរដ្ឋាភិបាលទាំងនេះមិនបានយល់ដឹងពីវិធីក្នុងការទំនាក់ទំនង និងឥទ្ធិពលរបស់យេនឌ័រ ក្នុងការអនុវត្តកម្មវិធី និងប្រតិបត្តិការអង្គការទេ ហើយបង្ហាញថា អង្គការរបស់ខ្លួនមិនយល់ពីគំនិតនៃការបញ្ចៀបយេនឌ័រទេ។ ឧទាហរណ៍ ៖ អ្នកផ្តល់បទសម្ភាសន៍មកពីអង្គការមិនមែនរដ្ឋាភិបាលធ្វើការងារលើផ្នែកសិទ្ធិមនុស្សបានចាត់ទុកយេនឌ័រ និងសិទ្ធិស្ត្រីក្នុងពេលកំពុងមានជម្លោះថាជាអាណត្តិការងាររបស់ខ្លួនដើម្បីលើកកម្ពស់ និងការពារសិទ្ធិមនុស្សសម្រាប់មនុស្សគ្រប់រូប។ ឧទាហរណ៍ ៖ អង្គការមិនមែនរដ្ឋាភិបាលខ្លះដែលមានការងារលើផ្នែកសិទ្ធិមនុស្សបានបានរាយការណ៍ថា ខ្លួននឹងគ្មានគម្រោងដែលផ្តោតការយកចិត្តទុកដាក់លើយេន ឌ័រទេ ពីព្រោះ ទស្សនវិស័យរបស់ខ្លួនចំពោះយេនឌ័រ ឬជាពិសេសស្ត្រីស្ថិតនៅខាងក្រៅអាណត្តិការងាររបស់អង្គការខ្លួន ក្នុងការដោះស្រាយបញ្ហាពាក់ព័ន្ធនានា ដូចជា សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ឬសិទ្ធិសេដ្ឋកិច្ចសង្គម។ បញ្ហានេះអាចបណ្តាលមកពីមូលហេតុដែលថា “យេនឌ័រ” ដែលជាសិទ្ធិដោយឡែកមួយនោះមិនត្រូវបានបញ្ចូលឲ្យបានពេញលេញនៅក្នុងឯកសារចែងពីសិទ្ធិមនុស្សឡើយ។

ម្យ៉ាងវិញទៀត បទសម្ភាសន៍ជាមួយអង្គការដែលមានការងារពាក់ព័ន្ធនឹងសិទ្ធិមនុស្ស បានបង្ហាញថា អង្គការរបស់ខ្លួនមិនយល់ដឹងថាតើយេនឌ័រទំនាក់ទំនង និងជះឥទ្ធិពលដល់កម្មវិធី/គម្រោង និងប្រតិបត្តិការទាំងអស់យ៉ាងណាឡើយ។ អង្គការទាំងនេះក៏មិនយល់ដឹងពីតម្លៃនៃការយល់ដឹងយេនឌ័រកាន់តែច្រើននៅក្នុងការងាររបស់ខ្លួន និងមានកង្វល់ដល់ការចំណាយសម្រាប់ការផ្លាស់ប្តូរនានានៅក្នុងសកម្មភាពអង្គការ។ ជាលទ្ធផល អង្គការមិនមែនរដ្ឋាភិបាលជាច្រើនមិនបានបញ្ចូលលក្ខខណ្ឌណាមួយនៃយេនឌ័រទេ ហើយក៏មិនបានបកស្រាយឲ្យបានច្បាស់ថាតើត្រូវលើកកម្ពស់សមភាពយេនឌ័រ និងធ្វើឲ្យសម្រេចសមភាពយេនឌ័រនៅក្នុងលទ្ធផលគម្រោងយ៉ាងណាឡើយ ដែលការណ៍នេះគឺជាបុរេលក្ខខណ្ឌដ៏ចាំបាច់មួយសម្រាប់ធានាឲ្យមានលទ្ធផលដែលមាននិរន្តរភាព។

សេចក្តីថ្លែងការណ៍នៅទីក្រុងវីយ៉ែន និងកម្មវិធីសកម្មភាពបញ្ជាក់ថា សិទ្ធិស្ត្រី និងកុមារី គឺជា “ផ្នែកមួយនៃសិទ្ធិមនុស្ស ដែលចាំបាច់ មិនអាចដកហូត និងមិនអាចបំបែកបានឡើយ” ដោយតម្រូវឲ្យមានការយកចិត្តទុកដាក់ជាពិសេសថា សិទ្ធិនេះគឺជាផ្នែកមួយនៃសកម្មភាពសិទ្ធិមនុស្សទាំងអស់។ សេចក្តីថ្លែងការណ៍បញ្ជាក់បន្ថែមទៀតពីការចាំបាច់ “ក្នុងការបញ្ចូល និងការបង្កលក្ខណៈងាយស្រួលឲ្យស្ត្រីចូលរួមឲ្យបានពេញលេញក្នុងឋានៈជាភ្នាក់ងារ និងជាអ្នកទទួលផលក្នុងដំណើរការអភិវឌ្ឍន៍[7]។

ដូចគ្នានេះដែរ គ្មានអង្គការមិនមែនរដ្ឋាភិបាលណាមួយក្នុងចំណោមអង្គការធ្វើការងារខាងសិទ្ធិមនុស្ស ដូចជាអង្គការក្រៅរដ្ឋាភិបាលដែលកំពុងធ្វើការក្នុងវិស័យអប់រំ និងការកសាងសន្តិភាព បានរាយការណ៍ថា យេនឌ័រមិនមែនសំដៅទៅលើតែបុរសនោះទេ ពីព្រោះពួកគេមានអាណត្តិការងារជាក់លាក់ដោយធ្វើការកំណត់យកអ្នកទទួលផលទាំងបុរស និងស្ត្រី។ ពួកគេក៏យល់ឃើញថា បញ្ហាយេនឌ័រគួតែជាចំណុចយកចិត្តទុកដាក់របស់អង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការងារជាមួយនឹងសិទ្ធិស្ត្រី។ ទោះជាយ៉ាងនេះក្តី បើទោះបីជាអ្នកផ្តល់បទសម្ភាសន៍មួយចំនួនបានយល់ដឹងកាន់តែច្រើនពីបញ្ហាយេនឌ័រអំឡុងពេលផ្តល់ សម្ភាសន៍ក៏ដោយ ក៏ពួកគាត់បញ្ជាក់ពីបំណងចង់សិក្សាបន្ថែមទៀត។

នៅក្នុងពេលសម្ភាស ជាមួយអ្នកផ្តល់បទសម្ភាសន៍ទាំងនោះ យើងមិនបានសិក្សាស្រាវជ្រាវ និងការវិភាគឲ្យបានស៊ីជម្រៅអំពីការប្រើប្រាស់ក្របខ័ណ្ឌ និងបទដ្ឋានច្បាប់អន្តរជាតិជាធរមាន ពាក់ព័ន្ធទៅនឹងការរើសអើងយេនឌ័រ និងអំពើហិង្សាលើផ្លូវភេទក្នុងពេលមានជម្លោះ។ អង្គការក្រៅរដ្ឋាភិបាលតិចតួចប៉ុណ្ណោះដែលបានផ្តល់បទសម្ភាសន៍ បាននិយាយយោងដល់តុលាការអន្តរជាតិ ដូចជា តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់រវ៉ាន់ដា (ICTR), តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី (ICTY), តុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន (SCSL), និងតុលាការឧក្រិដ្ឋកម្មអន្តរជាតិ (ICC) ឬ អនុសញ្ញាអន្តរជាតិពាក់ព័ន្ធ ដូចជាអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ (CEDAW) ដែលបានលើកឡើងជាពិសេសដល់ការលើកកម្ពស់សមភាពយេនឌ័រ និងការលើកកម្ពស់អំណាចរបស់ស្ត្រី។

[7]គោលការណ៍ទី៥ និងទី៣៦ នៃសេចក្តីថ្លែងការទីក្រុងវីយែន និងកម្មវិធីសកម្មភាព។ គោលការណ៍ទី៥ និងទី៣៦ នៃសេចក្តីថ្លែងការណ៍ ទីក្រុងវីយែន និងកម្មវិធីសកម្មភាពត្រូវបានអនុម័តដោយសន្និបាតពិភពលោក ស្តីពីសិទ្ធិមនុស្សនៅទីក្រុងវីយែននៅថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ ១៩៩៣។ អាចស្វែងរកតាមគេហទំព័រ៖ http://www2.ohchr.org/english/law/vienna.htm#wp1002434 (ទទួលបាននៅថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០១២។

២. វិធីសាស្ត្រជាយុទ្ធសាស្ត្រសម្រាប់លើកកម្ពស់សមភាពយេនឌ័រ

ការបង្កើតឲ្យមានវិធីសាស្ត្រយុទ្ធសាស្ត្រច្បាស់លាស់ដើម្បីលើកកម្ពស់សមភាពយេនឌ័រ គឺជាការងារសំខាន់របស់អង្គការមិនមែនរដ្ឋាភិបាល ដើម្បីឲ្យមានការយល់ដឹងយេនឌ័រឲ្យកាន់តែច្រើន ប៉ុន្តែទង្វើនេះកម្រប្រទះឃើញក្នុងការអនុវត្តជាក់ស្តែងណាស់។

ក្នុងចំណោមអង្គការមិនមែនរដ្ឋាភិបាលដែលបានផ្តល់បទសម្ភាសន៍ អង្គការភាគច្រើនបំផុតមានប្រព័ន្ធក្នុងកន្លែងធ្វើការងារដើម្បីកត់ត្រាចំនួនអ្នកទទួលផលដែលពាក់ព័ន្ធនឹងកម្មវិធី ឬគម្រោងរបស់ពួកគេ។ ទោះជាយ៉ាងនេះក្តី មានអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនតូចប៉ុណ្ណោះដែលបានបង្កើតប្រព័ន្ធដើម្បីបែងចែកទិន្នន័យតាមភេទ។ ទិន្នន័យបែងចែកតាមភេទគឺជាទិន្នន័យសំខាន់ ពីព្រោះទិន្នន័យដូចនេះផ្តល់ពត៌មានដល់បុគ្គលិកទាក់ទងនឹងការ ដាក់ស្ត្រីទៅក្នុងកម្មវិធីរបស់ពួកគេ និងអាចធ្វើឲ្យបុគ្គលិកទាំងនេះយល់ពីភាពខុសគ្នានៃបទពិសោធរបស់បុរស និងស្ត្រីតាមរយៈការផ្តល់សេវារបស់ពួកគេ។ ការធ្វើដូចនេះអាចធ្វើឲ្យបុគ្គលិកទាំងនេះកែសម្រួលសេវារបស់ខ្លួនឲ្យកាន់តែពាក់ព័ន្ធនឹងយេនឌ័រ និងឆ្លើយតបទៅតម្រូវការរបស់ស្ត្រីកាន់តែប្រសើរ។ កង្វះបែងចែក និងវិភាគទិន្នន័យបែងចែកតាមភេទជាលក្ខណៈប្រព័ន្ធមានន័យថា អង្គការមិនមែនរដ្ឋាភិបាលពុំមានព័ត៌មានដែលចាំបាច់ដើម្បីកំណត់ និងដោះស្រាយឧបសគ្គជាក់លាក់ដែលស្ត្រីជួបប្រទះ ក្នុងការទទួលបាន និងចូលរួមឲ្យបានពេញលេញក្នុងសេវានានា។ កង្វះខាតទិន្នន័យអាចបណ្តាលមកពីការធ្លាក់ចុះនៃការចូលរួមរបស់ស្ត្រីក្នុងកម្មវិធី ឬ គម្រោងរបស់អង្គការទាំងនេះ ។

ការខ្វះជំនាញយេនឌ័រក្នុងអង្គការក្រៅរដ្ឋាភិបាលដែលបានផ្តល់បទសម្ភាសន៍នេះ គឺជាឧបសគ្គដល់លទ្ធភាពរបស់ខ្លួនក្នុងការរៀបចំសកម្មភាពដោយផ្តោតការយកចិត្តទុកដាក់លើយេនឌ័រក្នុងយុត្តិធម៌អន្តរកាល និងពង្រឹងការយល់ដឹងយេនឌ័រនៅក្នុងអង្គការរបស់ខ្លួន។ អង្គការមិនមែនរដ្ឋាភិបាលទាំងនេះយល់ថា នេះគឺជាឧបសគ្គដ៏ធំដល់ ការបង្កើតកម្មវិធីឆ្លើយតបយេនឌ័រដែលមាននិរន្តរភាព។ ទោះជាយ៉ាងនេះក្តី អង្គការមិនមែនរដ្ឋាភិបាលមួយចំនួនតូចមានបុគ្គលិកដែលមានសមត្ថភាពខ្ពស់លើផ្នែកយេនឌ័រ ដូចនេះអង្គការទាំងនេះមានឱកាសកាន់ច្រើន ក្នុងការផ្សព្វផ្សាយការយល់ដឹងយេនឌ័រទៅក្នុងគោលនយោបាយអង្គការ និងសកម្មភាពការងាររបស់អង្គការ។ ដូច្នេះអង្គការក្រៅរដ្ឋាភិបាលដទៃទៀតគួតែត្រូវបានទទួលស្គាល់ពីអង្គការក្រៅរដ្ឋាភិបាលទាំងនេះ ហើយយកមកឆ្ពុះបញ្ចាំងពីបទពិសោធល្អៗ ពីព្រោះបទពិសោធទាំងនេះអាចលើកទឹកចិត្តអង្គការក្រៅរដ្ឋាភិបាល ដទៃទៀតឲ្យរៀបចំវិធីសាស្ត្រជាយុទ្ធសាស្ត្រដើម្បីលើកកម្ពស់សមភាពយេនឌ័រ។

៣. ការសងសឹក ប្រតិកម្មប្រឆាំង និងការបដិសេធ

ការខ្វះវិធីសាស្ត្រច្បាស់លាស់ក្នុងការលើកកម្ពស់សមភាពយេនឌ័រនៅក្នុងអង្គការមិនមែនរដ្ឋាភិបាលជាច្រើន អាចជាដើមចមឲ្យដល់ការយកចិត្តទុកដាក់តិចតួចដល់ការផ្តល់ការចូលរួមរបស់ស្ត្រីក្នុងដំណើរការយុត្តិធម៌អន្តរកាល ជាពិសេស នៅក្នុងកិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក ក្នុងឋាន:ជា “អ្នកបណ្តឹង” ជារួម និងជាពិសេសជា “ដើមបណ្តឹងរដ្ឋប្បវេណី”។ ជារួម អង្គការមិនមែនរដ្ឋាភិបាលដែលបានផ្តល់ សម្ភាសន៍ប្រឈមបញ្ហាការខ្វះការចូលរួមរបស់ស្ត្រីក្នុងការធ្វើការសម្រេច ទាក់ទងនឹងគោលនយោបាយ ការរៀបចំផែនការ ការរៀបគម្រោង ការរៀបចំថវិកា និងការបង្កើតកម្មវិធី។ ការខ្វះខាតនេះគឺជាឧបសគ្គដល់លទ្ធភាពរបស់អង្គការមិនមែនរដ្ឋាភិបាលទាំងនេះដើម្បីយល់ដឹងឲ្យបានពេញលេញពីហានិភ័យខ្ពស់ដែលអាចកើតមានចំពោះការចូលរួមរបស់ស្ត្រី មានជាអាទិ៍ ប្រតិកម្មប្រឆាំង ការសងសឹក និងការបដិសេធ។ អង្គការមិនមែនរដ្ឋាភិបាលមួយចំនួនបានរៀបចំ និងផ្តល់វិធានការការពារដល់ក្រុមគោលដៅរបស់ខ្លួន ជាពិសេស អ្នកចូលរួមជាស្ត្រីដែលជាញឹកញាប់បានចូលរួមក្នុងកិច្ចប្រជុំ សិក្ខាសាលា និងវេទិកាសាធារណៈ។ ទោះជាយ៉ាងនេះក្តី វិធានការទាំងនេះមិនគ្រប់គ្រាន់ក្នុងការការពារមិនឲ្យមានការសងសឹក ប្រតិកម្មប្រឆាំង ឬការបដិសេធពីអ្នកភូមិដូចគ្នា ឬសមាជិកគ្រួសាររបស់ខ្លួនផ្ទាល់។

៤. ការពង្រឹងការសម្របសម្រួល និងការសិក្សាពីមិត្តភក្តិ (ការចែករំលែកបទពិសោធល្អៗ)

អង្គការមិនមែនរដ្ឋាភិបាលមួយចំនួនបានបញ្ចូលវិធីសាស្ត្រឆ្លើយតបយេនឌ័រទៅក្នុងសកម្មភាពជាក់ស្តែងរបស់ខ្លួន និងបានទទួលពិន្ទុខ្ពស់នៅតាមសូចនាករ។ ការណ៍នេះមានន័យថា អង្គការទាំងនេះមានសកម្មភាព និងបទពិសោធក្នុងការឆ្លើយតបយេនឌ័រ។ ទោះជាយ៉ាងនេះក្តី ពិន្ទុរបស់អង្គការទាំងនេះមានគម្លាតខុសគ្នាយ៉ាងខ្លាំង។ អង្គការមិនមែនរដ្ឋាភិបាលដែលមានពិន្ទុទាបនៅលើមាត្រដ្ឋានវាយតម្លៃ នៅត្រូវការរយៈពេលវែងឆ្ងាយមុននឹងឈានទៅដល់ការផ្តល់សេវាឆ្លើយតបយេនឌ័រ។ ពេលនេះគឺជាឱកាសក្នុងការសិក្សាចំណេះដឹងពីយេនឌ័រពីមិត្តភក្តិ។ ជាងនេះទៀត កិច្ចការសំខាន់ចាំបាច់នោះគឺការសម្របសម្រួល និងការពង្រឹកសេវាបន្ថែម ពីព្រោះថា អង្គការមិនមែនរដ្ឋាភិបាលស្ទើរតែទាំងអស់ហាក់ដូចជាពឹងផ្អែកហួសហេតុលើសេវាកម្ម ឬ ជំនាញរបស់អង្គការក្រៅរដ្ឋាភិបាលមួយ ឬ ពីរប៉ុណ្ណោះ (TPO, CDP) ទាក់ទងនឹងការគាំទ្រផ្នែកចិត្តសង្គមដល់ជនរងគ្រោះដែលបានចូលរួមក្នុងគម្រោង/សេវានានា។

V. **អនុសាសន៍**

ផ្អែកលើសេចក្តីសន្និដ្ឋានខាងលើនេះ យើងផ្តល់អនុសាសន៍ដូចខាងក្រោម ៖

១. ការបញ្ចេញបទស្សនយេនឌ័រទៅក្នុងគោលនយោបាយ និងការអនុវត្តន៍ជាក់ស្តែង

កិច្ចការសំខាន់នោះគឺថា អង្គការមិនមែនរដ្ឋាភិបាល (ត្រូវបន្ត) លើកកម្ពស់ការយល់ដឹងយេនឌ័រក្នុងចំណោមបុគ្គលិករបស់ខ្លួន និងបង្ហាញថាតើយេនឌ័រមានទំនាក់ទំនងនឹងការងារក្នុងអង្គការរបស់ខ្លួនយ៉ាងណា។ ដើម្បីសម្រេចបានវត្ថុបំណងនេះ អ្នកផ្តល់បទសម្ភាសន៍ផ្តល់អនុសាសន៍លើយុទ្ធសាស្ត្រដូចខាងក្រោម ៖

- រៀបចំឲ្យមាន និងអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ
- ត្រូវជួលបុគ្គលិកទទួលបន្ទុកទំនាក់ទំនងផ្នែកយេនឌ័រ ដើម្បីផ្តល់វគ្គបណ្តុះបណ្តាល និងការប្រឹក្សាទាក់ទងនឹងសកម្មភាពយល់ដឹងយេនឌ័រ
- ផ្តល់ការបណ្តុះបណ្តាលក្នុងអង្គការឲ្យបានទៀងទាត់ស្តីពីសកម្មភាពយល់ដឹងយេនឌ័រ
- គាំទ្រការចូលរួមរបស់បុគ្គលិកក្នុងវគ្គបណ្តុះបណ្តាលនៅខាងក្រៅអង្គការឲ្យបានទៀងទាត់ស្តីពីសកម្មភាពយល់ដឹងយេនឌ័រ

២. រៀបចំឲ្យមានវិធីសាស្ត្រជាយុទ្ធសាស្ត្រជាក់ស្តែងដើម្បីធានាថា ស្ត្រីទទួលបានផលប្រយោជន៍ពីសកម្មភាព/គម្រោង

ដើម្បីធានាថា សកម្មភាព/គម្រោងរបស់អង្គការខ្លួនឆ្លើយតបស្មើៗគ្នាទៅនឹងតម្រូវការរបស់ស្ត្រីនោះ អ្នកផ្តល់ បទសម្ភាសន៍ផ្តល់អនុសាសន៍លើយុទ្ធសាស្ត្រដូចខាងក្រោម ៖

- ប្រសិនបើអនុវត្តបាន ពិគ្រោះជាមួយស្ត្រីដើម្បីស្វែងរកតម្រូវការជាក់លាក់របស់ស្ត្រី
- រៀបចំឲ្យមានប្រព័ន្ធមួយដើម្បីប្រមូលទិន្នន័យបែងចែកភេទ និងបង្កើតដំណើរការការងារដើម្បីធានាឲ្យមានការប្រមូលទិន្នន័យបែងចែកភេទ និងការវិភាគទិន្នន័យទាំងនេះជាប្រចាំ។ កម្រិត និងបទពិសោធរបស់ស្ត្រីដែលបានចូលរួមក្នុងសម្ភាសន៍ គួរយកមកវិភាគដើម្បីកំណត់រកឧបសគ្គណាមួយរបស់ ស្ត្រី ក្នុងការប្រើប្រាស់ ឬការចូលរួមឲ្យបានពេញលេញក្នុងសកម្មភាព/គម្រោង។
- ធ្វើការត្រួតពិនិត្យ និងវាយតម្លៃជាប្រចាំ ដើម្បីធានាឲ្យមានការកំណត់ឲ្យបានត្រឹមត្រូវនូវបញ្ហាយេនឌ័រ ឬឧបសគ្គ ហើយធានាឲ្យមានការដោះស្រាយបញ្ហាទាំងនេះឲ្យមានប្រសិទ្ធភាព។
- នៅពេលចាំបាច់ រៀបចំឲ្យមានគម្រោងផ្សេងៗ ដោយផ្តោតការយកចិត្តទុកដាក់លើស្ត្រី ដើម្បីបំពេញ តម្រូវការជាក់លាក់របស់ស្ត្រី។

៣. ការកាត់បន្ថយ និងការបង្ហាញផលប៉ះពាល់ជាអវិជ្ជមានដែលមានសក្តានុពលនៃការចូលរួមរបស់ស្ត្រី

- អង្គការមិនមែនរដ្ឋាភិបាលមានកាតព្វកិច្ចធានាថា អ្នកចូលរួមក្នុងកម្មវិធី/គម្រោង មិនត្រូវបង្កផលប៉ះពាល់ (វិធីសាស្ត្រមិនបង្កមហន្តរាយ)។ ដើម្បីធានាឲ្យមានការកាត់បន្ថយហានិភ័យរបស់អ្នកចូលរួម អ្នកផ្តល់បទសម្ភាសន៍ផ្តល់អនុសាសន៍លើយុទ្ធសាស្ត្រដូចខាងក្រោម ៖
- បង្កើនសមត្ថភាពរបស់ខ្លួន ដើម្បីឆ្លើយតបទៅនឹងតម្រូវការចិត្តសាស្ត្ររបស់កូនក្តី/ដើមបណ្តឹងរដ្ឋប្បវេណី ដោយមិនត្រូវពឹងផ្អែកទាំងស្រុងលើអង្គការចិត្តសង្គមអន្តរវប្បធម៌/ក្រុមអ្នកការពារសិទ្ធិកម្ពុជា (TPO/CDP) ដើម្បីបំពេញតម្រូវការរបស់ដើមបណ្តឹងរដ្ឋវេណីក្នុងការចូលរួមជាមួយ អ.វ.ត.ក ដែលកំពុងតែមានកំណើនជាពិសេសស្ត្រីដែលមានតម្រូវការពិសេសដើម្បីចូលរួមក្នុងសវនាការ ទាំងនៅមុន ក្នុងពេល និងក្រោយពេលសវនាការ។ បញ្ហានេះអាចដោះស្រាយបានតាមរយៈ ៖
  - ជួលអ្នកជំនាញផ្នែកអំពើហិង្សាផ្លូវភេទ/ពាក់ព័ន្ធនឹងយេនឌ័រ ដើម្បីផ្តល់ការគាំទ្រដល់កូនក្តី
  - អញ្ជើញអ្នកជំនាញឲ្យផ្តល់វគ្គបណ្តុះបណ្តាលក្នុងអង្គការសម្រាប់បុគ្គលិកដើម្បីឆ្លើយតបទៅនឹងតម្រូវការចិត្តសាស្ត្រ
  - ធានាថា បុគ្គលិកទាំងអស់មានការយល់ដឹងពីវិធីសាស្ត្រ “មិនបង្កមហន្តរាយ” និងអនុវត្តវិធីសាស្ត្រ នេះឲ្យបានត្រឹមត្រូវនៅក្នុងសកម្មភាពការងារ
- ស៊ើបអង្កេតដោយយកចិត្តទុកដាក់ និងកាត់បន្ថយហានិភ័យនៃការសងសឹក ប្រតិកម្មប្រឆាំង និងការបដិសេធដែលកូនក្តីរបស់ខ្លួនអាចប្រឈម ពីសំណាក់គ្រួសារ ឬសហគមន៍ ដោយសារតែការចូលរួមរបស់ស្ត្រីនៅក្នុងកម្មវិធី/គម្រោង។ លើកទឹកចិត្តកូនក្តីឲ្យរាយការណ៍ឧប្បត្តិហេតុនៃការសងសឹក ប្រតិកម្ម ប្រឆាំង និងការបដិសេធ ហើយសហការជាមួយដៃគូពាក់ព័ន្ធ រួមទាំង អ.វ.ត.ក និងអាជ្ញាធរមូលដ្ឋាន ដោះស្រាយបញ្ហាទាំងនេះ
- រៀបចំបង្កើត ឬ បញ្ចូលយុទ្ធសាស្ត្រ “មិនបង្កមហន្តរាយ” ទៅក្នុងគម្រោង ជាពិសេសសម្រាប់ស្ត្រីដែលចូលរួមក្នុងដំណើរការយុត្តិធម៌អន្តរកាល
- រៀបចំបង្កើតគោលនយោបាយ ឬបទបញ្ជាក្នុងអង្គការដោយមានចែងពីបទប្បញ្ញត្តិជាក់លាក់ស្តីពី “សម ភាពយេនឌ័រ ឬតំណាងយេនឌ័រដោយស្មើភាព” ក្នុងកម្រិតនៃការធ្វើសេចក្តីសម្រេច និងការផ្តល់សេវាកម្ម។ វិធានផ្នែកក្នុងទាំងនេះមានបញ្ចូលបទប្បញ្ញត្តិស្តីពី “ការទប់ស្កាត់ការបៀតបៀនផ្លូវភេទ និងយន្តការដាក់ពាក្យបណ្តឹង” ដោយមិនត្រូវមានការអត់ឱនដល់អំពើហិង្សា ហើយផ្តល់វិធានការដោះស្រាយឲ្យបានគ្រប់គ្រាន់។

៤. ការពង្រឹងការសម្របសម្រួល និងការសិក្សាពីមិត្តភក្តិ (ការចែករំលែកបទពិសោធល្អៗ)

ដើម្បីពង្រឹងការសម្របសម្រួល និងការសិក្សាពីមិត្តភក្តិ អ្នកផ្តល់បទសម្ភាសន៍ផ្តល់អនុសាសន៍លើយុទ្ធសាស្ត្រដូចខាងក្រោម ៖

- រៀបចំឲ្យមានកិច្ចសហប្រតិបត្តិការជាផ្លូវការក្នុងចំណោមអង្គការមិនមែនរដ្ឋាភិបាលនានា ជាពិសេស ការចែករំលែកធនធាន (ដូចជាការចងក្រងទិន្នន័យជម្លោះ) និងចំណេះដឹងស្តីពីបទពិសោធន៍ល្អៗទាក់ទងទៅនឹងការយល់ដឹងយេនឌ័រ និងការលើកកម្ពស់អំណាចរបស់ស្ត្រី។
- ស្ទើបអង្កេតសមិទ្ធលទ្ធភាពក្នុងការរៀបចំគម្រោងរួមគ្នាដើម្បីរៀបចំទិន្នន័យជម្លោះ ដើម្បីកត់ត្រាឯកសារពីអំពើហិង្សាដែលស្ត្រីបានឆ្លងកាត់ ផលបះពាល់ពីអំពើហិង្សា និងភាគីពាក់ព័ន្ធផ្សេងៗទៀត។
- ប្រសិនបើអាចធ្វើបាន បង្កើតគម្រោងភាពជាដៃគូរួម ក្នុងចំណោមអង្គការមិនមែនរដ្ឋាភិបាលដែលកំពុងធ្វើការងារនៅក្នុងវិស័យស្រដៀងគ្នា ជាពិសេស ស្តីពីស្ត្រី និងយេនឌ័រ ក្រៅពីបរិបទរបស់ អ.រ.ត.ក ដើម្បីឲ្យមានឥទ្ធិពលកាន់តែខ្លាំងឡើងនៃការលើកកម្ពស់អំណាចរបស់ស្ត្រី និងការឆ្លើយតបយេនឌ័រនៅក្នុងសង្គម។
- ការចូលរួមឲ្យបានសកម្មក្នុងវេទិកា ឬអង្គប្រជុំ ក្នុងការចងក្រងបណ្តាញការងារ និងចែករំលែកបទពិសោធល្អៗ និងមេរៀនជាបទពិសោធ។
- ចងក្រង និងផ្សព្វផ្សាយឲ្យបានទូលំទូលាយនូវការស្រាវជ្រាវពាក់ព័ន្ធ លទ្ធផលនៃការវាយតម្លៃ និងបទពិសោធគំរូល្អៗ។

អក្សរកាត់

ADHOC	សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (សមាគម អាដហុក)
AIJI	គម្រោងផ្តួចផ្តើមយុត្តិធម៌អន្តរជាតិអាស៊ី
ASF	អង្គការមេធាវីគ្មានព្រំដែន បារាំង
CDP	ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា
CEDAW	អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ
CHRAC	គណៈកម្មាធិការប្រព្រឹត្តកម្មនៃអង្គការ សមាគមការពារសិទ្ធិមនុស្សកម្ពុជា
CSOs	អង្គការសង្គមស៊ីវិល
DC-Cam	មជ្ឈមណ្ឌលឯកសារកម្ពុជា
ECCC	អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
GVB	អំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ
ICC	តុលាការឧក្រិដ្ឋកម្មអន្តរជាតិ
ICfC	មជ្ឈមណ្ឌលអន្តរជាតិសម្រាប់ការផ្សះផ្សា
ICTR	តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់រវ៉ាន់ដា
ICTY	តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី
LAC	អង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា
NGOs	អង្គការមិនមែនរដ្ឋាភិបាល
SCSL	តុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន
SGBV	អំពើហិង្សាពាក់ព័ន្ធនឹងផ្លូវភេទ និងយេនឌ័រ
TPO	អង្គការចិត្តសង្គម-អន្តរវប្បធម៌
UN SCR 1325	សេចក្តីសម្រេចលេខ ១៣២៥ របស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ
VSS	អង្គភាពគាំពារជនរងគ្រោះ
YfP	អង្គការយុវសន្តិភាព
YRDP	អង្គការកម្មវិធីអភិវឌ្ឍន៍ធនធានយុវជន

ឯកសារពិគ្រោះ

1. Caroline Moser, *"An Introduction to Gender Audit Methodology: Its Design and Implementation in DFID Malawi,"* Oversees Development Institute (ODI), May 2005

2. Theresa de Langis, *"The Result of ECCC Baseline Study on Gender Sensitivity in Transitional Justice Process,"* Victims Support Section of the Extraordinary Chambers in the Courts of Cambodia, March 2012

3. UNCT Performance Indicators for Gender Equality and Women's Empowerment, Version: 25th February 2008

4. UNDP/UNIFEM, *"A User's Guide to Measuring Gender-Sensitive Basic Service Delivery"* March 2009

5. United Nations Development Fund for Women, "A Window of Opportunity? Making Transitional Justice Work for Women," September 2010

6. World Conference on Human Rights, *"The Vienna Declaration and Program of Action"* (25 June 1993). Available at: http://www2.ohchr.org/english/law/vienna.htm#wp1002434 (retrieved on 20 April 2012)

បញ្ជីឈ្មោះអង្គការពាក់ព័ន្ធ

១. ADHOC ៖ សមាគមការពារសិទ្ធិមនុស្ស
និងអភិវឌ្ឍន៍នៅកម្ពុជា (សមាគម អាដហុក)
អាសយដ្ឋាន ៖ ផ្ទះលេខ ៣ ផ្លូវ ១៥៨ សង្កាត់ បឹងវាំង
ខណ្ឌដូនពេញ ភ្នំពេញ ប្រទេសកម្ពុជា ប្រអប់សំបុត្រលេខ
១០២៤
ទូរស័ព្ទ ៖ (៨៥៥-២៣) ២១៨ ៦៥៣/ ៩៩០ ៥៥៤
ទូរសារ ៖ (៨៥៥-២៣) ២១៧ ២២៩
សារអេឡិចត្រូនិក ៖ adhoc@forum.org.kh
គេហទំព័រ ៖ www.adhoc-cambodia.org

២. ASF ៖ អង្គការក្រុមមេធាវីគ្មានព្រំដែន
អាសយដ្ឋាន ៖ ផ្ទះលេខ ៧១ ផ្លូវលេខ ៥ សង្កាត់
ជ្រោយចង្វា ភ្នំពេញ ប្រទេសកម្ពុជា
ទូរស័ព្ទ ៖ (៨៥៥-២៣) ៧២២ ០៥១
ទូរសារ ៖ (៨៥៥-២៣) ៧២២ ០៥១
សារអេឡិចត្រូនិក ៖
projectetc@avocastssanfrontieres-france.org
គេហទំព័រ ៖ www.avocatssanfrontieres-france.org

៣. AIJI ៖ គម្រោងផ្តួចផ្តើមយុត្តិធម៌អន្តរជាតិនៅអាស៊ី
អាសយដ្ឋាន ៖ ផ្ទះលេខ ១៩៩ ផ្លូវ ៦៣ កែងផ្លូវ ៣០៦
សង្កាត់បឹងកេងកង ១ ខណ្ឌចំការមន ភ្នំពេញ
ប្រទេសកម្ពុជា
ទូរស័ព្ទ ៖ (៨៥៥-១២) ៨៩៣៤០៧
សារអេឡិចត្រូនិក ៖ aiji.krtmonitoring@gmail.com

៤. CDP ៖ ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា
អាសយដ្ឋាន ៖ ផ្ទះលេខ ៥៥៧ ផ្លូវ ៤៥០ សង្កាត់
ទួលទំពូង ២ ខណ្ឌ ចំការមន ភ្នំពេញ ប្រទេសកម្ពុជា
ទូរស័ព្ទ ៖ (៨៥៥-២៣) ២១៤ ០១៩/ ២១៤ ០២៩
សារអេឡិចត្រូនិក ៖ cdp@cdpcambodia.org
គេហទំព័រ ៖ www.cdpcambodia.org

៥. CHRAC ៖ គណៈកម្មាធិការប្រព្រឹត្តកម្មនៃអង្គការ សមាគមការពារសិទ្ធិមនុស្សកម្ពុជា
អាសយដ្ឋាន ៖ ផ្ទះលេខ ៩ Eo ផ្លូវ ៣៣០ សង្កាត់បឹង
កេងកង ៣ ខណ្ឌចំការមន ភ្នំពេញ ប្រទេសកម្ពុជា
ទូរស័ព្ទ ៖ (៨៥៥-២៣) ៣០១ ៤១៥/ ៣០៥ ៦០៩
ទូរសារ ៖ (៨៥៥-២៣) ២១៨ ៧៥៩
សារអេឡិចត្រូនិក ៖ Chracsecretary@yahoo.com
គេហទំព័រ ៖ www.chrac.org

៦. DC-Cam ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា
អាសយដ្ឋាន ៖ ផ្ទះលេខ ៦៦ មហាវិថីព្រះសីហនុ
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ ប្រទេសកម្ពុជា
ទូរស័ព្ទ ៖ (៨៥៥-២៣) ២១១ ៨៧៥
ទូរសារ ៖ (៨៥៥-២៣) ២០១ ៣៥៨
សារអេឡិចត្រូនិក ៖ dccam@online.com.kh
គេហទំព័រ ៖ www.dccam.org

៧. ICfC ៖ មជ្ឈមណ្ឌលអន្តរជាតិសម្រាប់ការផ្សះផ្សា
អាសយដ្ឋាន ៖ ផ្ទះលេខ ៦៩ មហាវិថីសុធារស
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ ប្រទេស កម្ពុជា
ទូរស័ព្ទ ៖ (៨៥៥-២៣) ៥៥៥ ០៩២៥
សារអេឡិចត្រូនិក៖ minea@centerforconciliation.org

៨. សមាគមជនរងគ្រោះក្បែមក្បាន្ត
អាសយដ្ឋាន ៖ ផ្ទះលេខ ១៥ ភូមិទ្រា សង្កាត់ស្ទឹង មានជ័យ
ខណ្ឌមានជ័យ ភ្នំពេញ ប្រទេសកម្ពុជា
ទូរស័ព្ទ ៖ (៨៥៥-១១) ៨០៧ ៧២៧
សារអេឡិចត្រូនិក ៖ info@ksemksan.org

គេហទំព័រ ៖ www.centreforconciliation.org

៩. LAC ៖ ជំនួយផ្លូវច្បាប់នៃកម្ពុជា

អាសយដ្ឋាន ៖ ផ្ទះលេខ ៥១ ផ្លូវ ៦០៨ សង្កាត់ បឹងកក់ ២
ខណ្ឌទួលគោក ភ្នំពេញ ប្រទេសកម្ពុជា
ទូរស័ព្ទ ៖ (៨៥៥-២៣) ៨៨៣ ៩១៤/ ៨៣៣៩២៤
គេហទំព័រ៖ www.lac.org.kh

១១. YfP ៖ អង្គការយុវសន្តិភាព

អាសយដ្ឋាន ៖ ផ្ទះលេខ ៤-៦ G ផ្លូវ ៥១៣ សង្កាត់
បឹងកក់ ១ ខណ្ឌទួលគោក ភ្នំពេញ
សារអេឡិចត្រូនិក ៖ admin@yfpcambodia.org
គេហទំព័រ ៖ www.yfpcambodia.org

**១៣. VSS/ECCC ៖ អង្គភាពគាំពារជនរងគ្រោះនៃ
អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

អាសយដ្ឋាន ៖ ផ្លូវជាតិលេខ ៤ សង្កាត់ចោមចៅ
ខណ្ឌដង្កោ ភ្នំពេញ ប្រទេសកម្ពុជា
ទូរស័ព្ទ ៖ (៨៥៥-២៣) ២១៩ ៨១៤
ទូរសារ ៖ (៨៥៥-២៣) ២១៩ ៨៤១
សារអេឡិចត្រូនិក ៖ info@eccc.gov.kh
គេហទំព័រ ៖ www.eccc.gov.kh

គេហទំព័រ ៖ www.ksemksan.org

១០. TPO ៖ អង្គការចិត្តសង្គម-អន្តរវប្បធម៌

អាសយដ្ឋាន ៖ ផ្ទះលេខ ២ & ៤ កែងផ្លូវហាណូយ
និងផ្លូវឧកញ៉ាវ៉ាំង សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ
ប្រអប់សំបុត្រលេខ ១១២៤ ភ្នំពេញ ប្រទេសកម្ពុជា
ទូរស័ព្ទ ៖ (៨៥៥-២៣) ៦៣៦៦ ៩៩៣/ ៦៣៦៦ ៩៩២
សារអេឡិចត្រូនិក ៖ admin@tpocambodia.org

១២. YRDP ៖ អង្គការកម្មវិធីអភិវឌ្ឍន៍ធនធានយុវជន

អាសយដ្ឋាន ៖ ៩៣ ផ្លូវ ៥៩០ សង្កាត់បឹងកក់ ២
ខណ្ឌទួលគោក ភ្នំពេញ ប្រទេសកម្ពុជា
ទូរស័ព្ទ ៖ (៨៥៥-២៣) ៨៨០ ១៩៤
ទូរសារ ៖ (៨៥៥-២៣) ៧៥៥ ៩៣៣
សារអេឡិចត្រូនិក ៖ info@yrdp.org
គេហទំព័រ ៖ www.yrdp.org